ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 1

# ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

## Presentation of Financial Statements

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**”របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ”នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ងី តាយី**

## សេចក្តីផ្តើម (ស.ផ)

ស.ផ ១ ស្តង់ដាគណនេយ្យអន្តរជាតិ១ ស្តីពី *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ*( ស.គ.អ ១ ) ជំនួស ស.គ.អ ១ ស្តីពី *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* (បានកែប្រែឆ្នាំ ២០០៣) ហើយដែលបានធ្វើវិសោធនកម្មឆ្នាំ២០០៥។ កំណត់នូវការតម្រូវទូទៅសម្រាប់ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ គោលការណ៍ណែនាំនានាសម្រាប់រចនាសម្ព័ន្ធនៃរបាយការណ៍នោះ ព្រមទាំងតម្រូវការអប្បរមា សម្រាប់មាតិការបស់របាយការណ៍។

## ហេតុផលក្នុងការធ្វើការកែតម្រូវ ស.គ.អ ១

ស.ផ ២ គោលដៅចម្បងរបស់ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ ក្នុងការ កែប្រែ ស.គ.អ ១ គឺ ដើម្បីបញ្ចូលព័ត៌មានក្នុង របាយការណ៍ ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននៃចរិកលក្ខណៈចែករំលែក។ នៅក្នុងគោលដៅនេះ ក្រុមប្រឹក្សាបានចាត់ទុកថា វាមានអត្ថប្រយោជន៍ ក្នុងការញែកចេញនូវ ការប្រែប្រួលលើមូលធនផ្ទាល់ (ទ្រព្យសកម្មសុទ្ធ ) របស់អង្គភាពដែលកើតពីប្រតិបត្តិការ ជាមួយម្ចាស់ហ៊ុនក្នុងនាមជាម្ចាស់ ក្នុងកំឡុងការិយបរិច្ឆេទមួយ ពីការប្រែប្រួលនានាលើមូលធនផ្ទាល់ ។ ដូចនេះ ក្រុមប្រឹក្សាបានសម្រេចថា រាល់ការប្រែប្រួលលើមូលធនផ្ទាល់របស់ម្ចាស់ហ៊ុនត្រូវតែបាន បង្ហាញនៅក្នុងរបាយការណ៍ ស្តីពីការប្រែប្រួលមូលធនផ្ទាល់ ដាច់ដោយឡែកពីការប្រែប្រួលលើមូលធនផ្ទាល់របស់អ្នកមិនមែនជាម្ចាស់ហ៊ុន ។

ស.ផ៣ តាមការពិនិត្យឡើងវិញរបស់ខ្លួន ក្រុមប្រឹក្សាក៏បានពិចារណាលើ សេចក្តីថ្លែងការណ៍ លេខ១៣០ របស់ក្រុមប្រឹក្សាស្តង់ដាគណនេយ្យ ហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិកស្តីពី *ការរាយការណ៍អំពីចំណូល* សរុបរួម

(SFAS130) ដែលបានចេញផ្សាយឆ្នាំ១៩៩៧ ។ ការតម្រូវនានានៅក្នុង ស.គ.អ ១ ចំពោះការបង្ហាញអំពីរបាយការណ៍ស្ដីពីចំណូល សរុបរួមគឺប្រហាក់ប្រហែល នឹងការតម្រូវនៅក្នុង SFAS130 ដែរ ប៉ុន្តែភាពខុសគ្នាមួយចំនួននៅតែមាន ហើយភាពខុសគ្នាទាំងនោះត្រូវបានបញ្ជាក់ នៅក្នុងកថាខណ្ឌ ម.ស ១០៦ នៃមូលដ្ឋាននៃការសន្និដ្ឋាន ។

ស.ផ ៤ បន្ថែមលើសពីនេះទៀតបំណងរបស់ក្រុមប្រឹក្សា ក្នុងការកែតម្រូវ ស.គ.អ ១ គឺដើម្បីធ្វើឱ្យប្រសើរឡើង និងធ្វើឱ្យត្រូវតាមលំដាប់ លំដោយឡើងវិញ នៃផ្នែកនានានៃ ស.គ.អ ១ដើម្បីឱ្យវាមានភាព ងាយស្រួលអាន ។ គោលដៅរបស់ក្រុមប្រឹក្សាមិនមែនដើម្បីពិចារណាឡើងវិញលើរាល់ការតម្រូវទាំងអស់ក្នុង ស.គ.អ ១ នោះទេ ។

## លក្ខណៈពិសេសសំខាន់ៗរបស់ ស.គ.អ ១

ស.ផ ៥ ស.គ.អ ១ ប៉ះពាល់ដល់ការបង្ហាញអំពីការប្រែប្រួលមូលធនផ្ទាល់ របស់ម្ចាស់ហ៊ុន និងការបង្ហាញអំពីចំណូលបន្ទាប់បន្សំ ។ វាមិនផ្លាស់ប្តូរការទទួលស្គាល់ ការវាស់វែងឬការលាតត្រដាងពីប្រតិបត្តិការពិសេស ព្រមទាំងព្រឹត្តិការណ៍ដទៃទៀតដែលតម្រូវដោយស្តង់ដានៃការរៀបចំរបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ នោះទេ ។

ស.ផ ៦ ស.គ.អ ១ តម្រូវឱ្យអង្គភាពមួយបង្ហាញនៅក្នុងរបាយការណ៍ស្តីពី ការប្រែប្រួលមូលធនផ្ទាល់នូវរាល់ការប្រែប្រួលទាំងអស់នៃមូលធន ផ្ទាល់របស់ម្ចាស់ហ៊ុន។រាល់ការប្រែប្រួលមូលធនផ្ទាល់របស់អ្នកដែល មិនមែនជាម្ចាស់ហ៊ុន (ដូចជាចំណូលសរុបរួម) ត្រូវបានតម្រូវឱ្យធ្វើការ បង្ហាញក្នុងរបាយការណ៍តែមួយនៃចំណូល សរុបរួម ឬក្នុងរបាយការណ៍ពីរ (របាយការណ៍លទ្ធផលដាច់ដោយឡែក និង របាយការណ៍នៃ ចំណូលបន្ទាប់បន្សំ )។ សមាសធាតុនៃ ចំណូលបន្ទាប់បន្សំមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបង្ហាញក្នុងរបាយការណ៍ ស្តីពីការប្រែប្រួលមូលធនផ្ទាល់ ។

ស.ផ ៧ ស.គ.អ ១ តម្រូវឱ្យអង្គភាពមួយបង្ហាញអំពីរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ នាដើមការិយបរិច្ឆេទប្រៀបធៀបចុងក្រោយបង្អស់ក្នុងសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលអង្គភាពអនុវត្ត ប្រតិសកម្មគោលនយោបាយគណនេយ្យ ឬធ្វើការរាយការណ៍ប្រតិសកម្ម ដូចដែលបានកំណត់នៅក្នុង ស.គ.អ៨ ស្តីពី *គោលនយោបាយគណនេយ្យ ការប្រែប្រួលនៃការប៉ាន់ស្មានគណនេយ្យនិងការភ័ន្តច្រឡំ* ឬនៅពេលដែលអង្គភាពធ្វើការចាត់ថ្នាក់ឡើងវិញលើធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ស.ផ ៨ ស.គ.អ ១ តម្រូវឱ្យអង្គភាពលាតត្រដាងព័ត៌មានអំពីការចាត់ថ្នាក់ ឡើងវិញនូវការកែតម្រូវនានានិងពន្ធលើប្រាក់ចំណូលទាក់ទិនទៅនឹង សមាសធាតុនីមួយៗនៃចំណូលបន្ទាប់បន្សំដទៃទៀត។ ការចាត់ថ្នាក់ ឡើងវិញនូវការកែតម្រូវនានា គឺជាបរិមាណទឹកប្រាក់ដែលបានចាត់ ថ្នាក់ឡើងវិញនៅក្នុងចំណេញ ឬខាតក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ដែល ត្រូវបានទទួលស្គាល់ពីមុនក្នុងចំណូលបន្ទាប់បន្សំដទៃទៀត ។

ស.ផ ៨ ស.គ.អ ១ តម្រូវឱ្យមានការបង្ហាញអំពីភាគលាភដែលបានទទួលស្គាល់ថាជាវិភាគទានចំពោះម្ចាស់ហ៊ុននិងថាជាបរិមាណទឹកប្រាក់ក្នុងមួយសន្លឹកហ៊ុនក្នុងរបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ ឬ នៅក្នុងកំណត់សម្គាល់។ភាគលាភ គឺជាវិភាគទានចំពោះម្ចាស់ហ៊ុន ក្នុងនាមជាម្ចាស់ហ៊ុន ហើយរបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ បង្ហាញនូវរាល់ការប្រែប្រួលទាំងអស់នៃមូលធនផ្ទាល់ ។

ស.ផ ១០ ការប្រែប្រួលចម្បងៗពី ស.គ.អ ១ ដែលបានបោះផ្សាយមុនត្រូវបានពិពណ៌នាដូចខាងក្រោម។

សំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ

ស.ផ ១១ ស.គ.អ ១ ដែលបានបោះផ្សាយមុនៗ ប្រើចំណងជើង “តារាងតុល្យការ” និង “របាយការណ៍លំហូរសាច់ប្រាក់” ដើម្បីពិពណ៌នានូវរបាយការណ៍ពីរ នៅក្នុងសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ។ ស.គ.អ ១ ប្រើពាក្យ “របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ” និង “របាយការណ៍លំហូរសាច់ប្រាក់” សម្រាប់របាយការណ៍ទាំងនោះ។ ចំណងជើងថ្មីឆ្លុះបញ្ចាំងកាន់តែជិតអំពីតួនាទីរបស់របាយការណ៍ទាំងនោះ ដូចដែលបាន លើកឡើងនៅក្នុង *ក្របខណ្ឌស្តង់ដា* * (សូមមើលកថាខណ្ឌ ម.ស ១៤-ម.ស ២១ នៃមូលដ្ឋាននៃការសន្និដ្ឋាន)។

ស.ផ ១២ ស.គ.អ ១ តម្រូវឱ្យអង្គភាពមួយលាតត្រដាងព័ត៌មានប្រៀបធៀបចំពោះការិយបរិច្ឆេទមុនៗ ដូចជា តម្រូវឱ្យលាតត្រដាងយ៉ាងហោចណាស់របាយការណ៍មួយក្នុងចំណោមរបាយការណ៍ពីរ និងក្នុងកំណត់សម្គាល់ពាក់ព័ន្ធ។ស្តង់ដានេះ បង្កើតនូវការតម្រូវមួយ ដើម្បីបញ្ចូលក្នុងសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ នូវរបាយការណ៍ស្តីពី ស្ថានភាពហិរញ្ញវត្ថុ នាដើមការិយបរិច្ឆេទប្រៀបធៀបចុងក្រោយបង្អស់ នៅពេលណាក៏ដោយ ដែលអង្គភាពអនុវត្តប្រតិសកម្មនូវគោលនយោបាយគណនេយ្យ ឬធ្វើការរាយការណ៍ប្រតិសកម្មនូវធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ឬនៅពេលដែលអង្គភាពចាត់ថ្នាក់ ឡើងវិញនូវធាតុទាំងនោះក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ។ គោលបំណងនោះ គឺដើម្បីផ្តល់នូវព័ត៌មានដែលមានប្រយោជន៍ក្នុងការវិភាគលើរបាយ

ការណ៍ ហិរញ្ញវត្ថុរបស់អង្គភាព (សូមមើលកថាខណ្ឌ ម.ស ៣១ និង ម.ស ៣២ នៃមូលដ្ឋាននៃការសន្និដ្ឋាន)។

ការរាយការណ៍អំពីការប្រែប្រួលមូលធនផ្ទាល់របស់ម្ចាស់ហ៊ុន និងចំណូលបន្ទាប់បន្សំ

ស.ផ ១៣ ស.គ.អ ១ ដែលបានបោះផ្សាយពេលមុន បានតម្រូវឱ្យមានការបង្ហាញនូវរបាយការណ៍លទ្ធផល ដែលបានបញ្ចូលនូវធាតុនានា នៃចំណូល និងចំណាយ ដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។ វាក៏តម្រូវឱ្យធាតុនានានៃចំណូល និងចំណាយដែលមិនបានទទួលស្គាល់ ក្នុងចំណេញ ឬខាត ត្រូវតែបានបង្ហាញនៅក្នុងរបាយការណ៍ ស្តីពីការប្រែប្រួលមូលធនផ្ទាល់។ ស្តង់ដានេះ ក៏បានដាក់ឈ្មោះឱ្យរបាយការណ៍ស្តីពី ការប្រែប្រួលមូលធនផ្ទាល់ដែលមានចំណេញឬខាត និងធាតុផ្សេងទៀតនៃចំណូលនិងចំណាយ ព្រមទាំងឥទ្ធិពលនៃការប្រែប្រួលលើគោលនយោបាយគណនេយ្យ និងការកែតម្រូវលើ ការភ័ន្តច្រឡំថាជា "របាយការណ៍ស្តីពីចំណូលនិងចំណាយ ដែលបានទទួលស្គាល់"។ ស.គ.អ ១ ឥឡូវនេះ បានតម្រូវថា:

(ក) ការប្រែប្រួលមូលធនផ្ទាល់ទាំងអស់ដែលកើតពីប្រតិបត្តិការ ជាមួយម្ចាស់ហ៊ុន ក្នុងនាមជាម្ចាស់ហ៊ុន (មានដូចជាការប្រែប្រួល មូលធនផ្ទាល់របស់ម្ចាស់) ត្រូវតែបានបង្ហាញដាច់ដោយឡែកពីការប្រែប្រួលមូលធនផ្ទាល់របស់អ្នកដែលមិនមែនជាម្ចាស់ហ៊ុន ។ អង្គភាពមិនត្រូវបានអនុញ្ញាតឱ្យបង្ហាញនូវសមាសធាតុនានា នៃចំណូលបន្ទាប់បន្សំ (មានដូចជា ការប្រែប្រួលមូលធនផ្ទាល់របស់អ្នកដែលមិនមែនជាម្ចាស់ហ៊ុន)ក្នុងរបាយការណ៍ស្តីពីការ ប្រែប្រួលមូលធនផ្ទាល់ ។ គោលបំណងគឺថាផ្តល់នូវព័តិមានដ៏ល្អ ដោយការប្រមូលបញ្ចូលគ្នានូវធាតុនានាដែលមានចរិកលក្ខណៈ ដែលអាចចែករំលែកបាន និងដោយបែងចែកធាតុនានាជាមួយ ចរិកលក្ខណៈខុសគ្នា (សូមមើលកថាខណ្ឌ ម.ស ៣៧ និង ម.ស ៣៨ នៃមូលដ្ឋាននៃការសន្និដ្ឋាន)។

(ខ) ចំណូល និងចំណាយត្រូវតែបានបង្ហាញនៅក្នុងរបាយការណ៍ តែមួយ (របាយការណ៍ស្តីពីចំណូលសរុបរួម ) ឬក្នុងរបាយការណ៍ ពីរ (របាយការណ៍លទ្ធផលដាច់ដោយឡែក និងរបាយការណ៍ស្តីពីចំណូលបន្ទាប់បន្សំ) ដាច់ដោយឡែកពីការប្រែប្រួលមូល ធនផ្ទាល់របស់ម្ចាស់ ( សូមមើលកថាខណ្ឌ ម.ស ៤៩ - ម.ស ៥៤ នៃមូលដ្ឋាននៃការសន្និដ្ឋាន )។

(គ) សមាសធាតុនានានៃចំណូលបន្ទាប់បន្សំដទៃទៀតត្រូវតែបង្ហាញនៅក្នុងរបាយការណ៍ចំណូលសរុបរួម ។

(ឃ) ចំណូលសរុបរួមដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*ការសម្អាងដល់ *ក្របខណ្ឌស្តង់ដា* គឺជា *ក្របខណ្ឌស្តង់ដារបស់ IASC* ស្តីពី *ការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* ស្តង់ដាគណនេយ្យអន្តរជាតិ (IASB) ។ នៅខែ កញ្ញា ឆ្នាំ ២០១០ ក្រុមប្រឹក្សាចុងក្រោយនេះបានជំនួស *ក្របខណ្ឌស្តង់ដា* ដោយ *ក្របខណ្ឌទស្សនទានស្តង់ដាសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ* ។

អំពីចំណូលបន្ទាប់បន្សំដទៃទៀត - ការចាត់ថ្នាក់ឡើងវិញនូវការកែតម្រូវនិងអានុភាពចំពោះពន្ធដែលពាក់ព័ន្ធ

**ស.ផ ១៤** ស.គ.អ ១ តម្រូវឱ្យអង្គភាពមួយលាតត្រដាង ព័ត៌មានអំពីពន្ធលើ ប្រាក់ចំណូលពាក់ព័ន្ធនឹងសមាសធាតុនិមួយៗ នៃចំណូលបន្ទាប់បន្សំ ដទៃទៀត ។ ស.គ.អ ១ ដែលបានបោះផ្សាយពេលមុន មិនបានបញ្ចូលការតម្រូវបែបនេះទេ ។ គោលបំណងគឺ ដើម្បីផ្តល់ព័ត៌មានដល់អ្នក ប្រើប្រាស់អំពីពន្ធពាក់ព័ន្ធនឹងសមាសធាតុទាំងនោះ ពីព្រោះសមាសធាតុនោះតែងតែមានអត្រាពន្ធ ដែលខុសពីពន្ធអនុវត្តចំពោះចំណេញឬខាត (សូមមើលកថាខណ្ឌ ម.ស ៦៥ - ម.ស ៦៨ នៃមូលដ្ឋាន នៃការសន្និដ្ឋាន)។

ស.ផ ១៥ ស.គ.អ ១ ក៏បានតម្រូវផងដែរថា អង្គភាពមួយត្រូវលាតត្រដាងអំពី ការចាត់ថ្នាក់ឡើងវិញនូវការកែតម្រូវដែលពាក់ព័ន្ធនឹងសមាសធាតុនៃ ចំណូលបន្ទាប់បន្សំដទៃទៀត ។ ការចាត់ថ្នាក់ឡើងវិញនូវការកែតម្រូវគឺ ជាបរិមាណទឹកប្រាក់ដែលបានចាត់ថ្នាក់ឡើងវិញនៅក្នុងចំណេញឬខាតនាការិយបរិច្ឆេទបច្ចុប្បន្ន ដែលត្រូវបានទទួលស្គាល់នៅក្នុង ចំណូលបន្ទាប់បន្សំដទៃទៀតនាការិយបរិច្ឆេទមុនៗ ។ គោលបំណងគឺផ្តល់ដល់អ្នកប្រើប្រាស់នូវព័ត៌មាន ដើម្បីវាយតម្លៃដល់អានុភាពរបស់ការចាត់ថ្នាក់ឡើងវិញនេះលើចំណេញឬខាត (សូមមើលកថាខណ្ឌ ម.ស ៦៩ - ម.ស ៧៣ នៃមូលដ្ឋាននៃការសន្និដ្ឋាន) ។

## ការបង្ហាញអំពីភាគលាភ

ស.ផ ១៦ **ស.គ.អ ១ ដែលបានបោះផ្សាយពេលមុន** បានអនុញ្ញាតឱ្យលាតត្រដាងព័ត៌មានអំពីបរិមាណនៃភាគលាភ ដែលបានទទួលស្គាល់ថាជាវិភាគទានចំពោះអ្នកកាន់មូលធនផ្ទាល់ (ដែលឥឡូវសំដៅដល់ម្ចាស់ហ៊ុន) និងបរិមាណ ទឹកប្រាក់ក្នុងមួយចំណែកហ៊ុន ដែលមានការពាក់ព័ន្ធនៅក្នុងរបាយការណ៍លទ្ធផល នៅក្នុងរបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ ឬនៅក្នុងកំណត់សម្គាល់ ។ **ស.គ.អ ១** តម្រូវឱ្យភាគលាភដែលបានទទួលស្គាល់ថាជាវិភាគទានចំពោះម្ចាស់ហ៊ុននិងបរិមាណទឹកប្រាក់ក្នុងមួយចំណែកហ៊ុនត្រូវតែបានបង្ហាញនៅក្នុងរបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ ឬនៅក្នុងកំណត់សម្គាល់។ ការបង្ហាញអំពីការលាត-ត្រដាងបែបនេះនៅក្នុងរបាយការណ៍ ស្តីពីចំណូលបន្ទាប់បន្សំ មិនត្រូវបានអនុញ្ញាតទេ (សូមមើលកថាខណ្ឌ ម.ស ៧៥ នៃ មូលដ្ឋាននៃការសន្និដ្ឋាន)។ គោលបំណងគឺដើម្បី ធានាថា ការប្រែប្រួលមូលធនផ្ទាល់របស់ម្ចាស់ហ៊ុន (ក្នុងករណីនេះ ជាវិភាគទានចំពោះម្ចាស់ហ៊ុនក្នុងទម្រង់ជាភាគលាភ) ត្រូវបានបង្ហាញដាច់ដោយឡែកពីការប្រែប្រួលមូលធន

ផ្ទាល់របស់អ្នកមិនមែនជាម្ចាស់ហ៊ុន (ដែលបានបង្ហាញនៅក្នុងរបាយ-ការណ៍ស្តីពីចំណូលបន្ទាប់បន្សំ) ។

## ស្តង់ដាគណនេយ្យអន្តរជាតិ ១
## ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

### គោលបំណង

១ ស្តង់ដារនេះរៀបរាប់ពីមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំ-ណងទូទៅ ដើម្បីធានានូវលទ្ធភាពប្រៀបធៀបទាំងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព និងទាំងជាមួយរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពផ្សេងទៀត។ វាកំណត់នូវការតម្រូវជាទូទៅសម្រាប់ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ គោលការណ៍ណែនាំសម្រាប់ទម្រង់ និងការតម្រូវអប្បរមា នៃមាតិការរបស់របាយការណ៍ហិរញ្ញវត្ថុ ។

### វិសាលភាព

២ អង្គភាពត្រូវអនុវត្តស្តង់ដានេះដើម្បីរៀបចំនិងបង្ហាញរបាយការណ៍ ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅ ស្របតាមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ។

៣ ស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដទៃទៀត កំណត់នូវលក្ខខណ្ឌតម្រូវសម្រាប់ទទួលស្គាល់ការវាស់វែងនិងការលាតត្រដាង ព័ត៌មាន សម្រាប់សកម្មភាពពិសេសនិងព្រឹត្តិការណ៍ផ្សេងទៀត ។

៤ ស្តង់ដានេះមិនអនុវត្តចំពោះ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបរួមបណ្តោះអាសន្ន ដែលត្រូវបានរៀបចំស្របតាម ស្តង់ដាគណនេយ្យ អន្តរជាតិ ៣៤ ស្តីពី *ការរាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន*។ ទោះបីជា យ៉ាងណាក៏ដោយ កថាខណ្ឌ ១៥-៣៥ អនុវត្តចំពោះ របាយការណ៍ហិរញ្ញ-វត្ថុទាំងនោះ ។ ស្តង់ដានេះ អនុវត្តដូចគ្នាដែរចំពោះគ្រប់អង្គភាព រួមទាំងអង្គ

ភាពដែលបង្ហាញ របាយការណ៍ហិរញ្ញវត្ថុរួម និងអង្គភាពដែលបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ដូចដែលបានកំណត់នៅក្នុងស្តង់ដា ២៧ ស្តីពី*របាយការណ៍ហិរញ្ញវត្ថុរួមនិងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*។

៥ ស្តង់ដានេះប្រើបច្ចេកសព្ទ ដែលសមស្របជាមួយនឹងអង្គភាពស្វែងរកប្រាក់ចំណេញ ដែលរួមមានទាំងអង្គភាពពាណិជ្ជកម្មរបស់រដ្ឋ។ ប្រសិនបើជា អង្គភាពមិនស្វែងរកប្រាក់ចំណេញនៅក្នុងវិស័យឯកជន ឬវិស័យសាធារណៈ ចង់អនុវត្តស្តង់ដានេះ អង្គភាពទាំងនោះអាចត្រូវធ្វើវិសោធនកម្មលើការពិពណ៌នា ដែលត្រូវបានប្រើសម្រាប់ធាតុជាក់លាក់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់របាយការណ៍ហិរញ្ញវត្ថុ ខ្លួនវាផ្ទាល់ ។

៦ ស្រដៀងគ្នានេះ អង្គភាពដែលមិនមានមូលធនផ្ទាល់ដូចបានកំណត់ក្នុង ស.គ.អ ៣២ ស្តីពី ឧបករណ៍ហិរញ្ញវត្ថុៈ *ការដាក់បង្ហាញ* (ឧ.សង្គហធនមួយចំនួន)និងអង្គភាពដែលមូនធនជា បណ្ណ័ភាគហ៊ុនរបស់ខ្លួនមិនមែនជាមូលធនផ្ទាល់ (ឧ. អង្គភាពសហប្រតិបត្តិការខ្លះ) អាចត្រូវសម្រួលការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ នៃភាគកម្មរបស់សមាជិក ឬភាគកម្មនៃការគ្រប់គ្រងរួមគ្នា ។

## និយមន័យ

៧ ពាក្យបច្ចេកទេសខាងក្រោមនេះត្រូវបានប្រើប្រាស់ក្នុងស្តង់ដានេះដែលមានន័យដូចតទៅ :

**របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ** (សំដៅដល់របាយការណ៍ហិរញ្ញវត្ថុ) ជារបាយការណ៍ដែលមានបំណងបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ដែលមិនមានតួនាទីតម្រូវឱ្យអង្គភាពរៀបចំ របាយការណ៍តាមតម្រូវការដោយឡែកសម្រាប់ព័ត៌មានដែលគេចង់បាន ។

**ដែលមិនអាចអនុវត្តបាន** មានន័យថា ការអនុវត្តលក្ខខណ្ឌតម្រូវមួយ មិនអាចអនុវត្តបាននៅពេលដែលអង្គភាពមិនអាចអនុវត្តវាបន្ទាប់ពីបាន ព្យាយាមអស់លទ្ធភាពក្នុងការអនុវត្ត ។

**ស្តង់ដានៃការរៀបចំបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ** គឺជាស្តង់ដា និងការបកស្រាយនានា ដែលចេញដោយ **ក្រុមប្រឹក្សាស្តង់ដាគណនេយ្យ អន្តរជាតិ (ក.ស.គ.អ)**។ ស្តង់ដានេះ មាន :

(ក) ស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ

(ខ) ស្តង់ដាគណនេយ្យអន្តរជាតិ

(គ) ការបកស្រាយរបស់ **គណៈកម្មាធិការបកស្រាយស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ**

(ឃ) ការបកស្រាយរបស់**គណកម្មាធិការអចិន្ត្រៃយ៍បកស្រាយស្តង់ដា**។

**ជាសារវន្ត** មានន័យថា ការលុបចោលឬការរាយការណ៍ខុសលើធាតុនានាដែលមានលក្ខណៈជាសារវ័ន្ត ប្រសិនបើការលុបចោល ឬការរាយការណ៍ខុសនោះមានឥទ្ធិពលដាច់ដោយឡែក ឬជារួម លើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច ដែលធ្វើឡើងដោយអ្នកប្រើប្រាស់ ដោយឈរលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុ។ភាពជាសារវន្តអាស្រ័យលើទំហំ និងប្រភេទនៃការលុបចោល ឬការរាយការណ៍ខុស ដែលបានធ្វើឡើងតាមកាលទេសៈ នៅជុំវិញ ។ ទំហំ ឬប្រភេទនៃសមាសធាតុ ឬទាំងទំហំនិងប្រភេទអាចជាកត្តាកំណត់។ ការវាយតម្លៃថាតើការលុប ឬការរាយការណ៍ខុស អាចជះឥទ្ធិពលលើសេចក្តីសម្រេចចិត្តរបស់អ្នកប្រើប្រាស់ ហើយដូចនេះវាមាន លក្ខណៈជាសារវន្តដែលតម្រូវឱ្យពិចារណាឡើងវិញលើចរិកលក្ខណៈរបស់ អ្នកប្រើ

ប្រាស់ទាំងនោះ។**ក្របខណ្ឌសម្រាប់ការរៀបចំនិងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ** ដែលបានលើកឡើងក្នុងកថាខណ្ឌ២៥* ដែល "អ្នកប្រើប្រាស់ត្រូវបានសន្មត់ថា មានចំណេះដឹងផ្នែកអាជីវកម្មនិងសកម្មភាពសេដ្ឋកិច្ច ព្រមទាំងចំណេះដឹង ផ្នែកគណនេយ្យគ្រប់គ្រាន់ និងមានបំណងសិក្សាលើព័ត៌មានដោយយក ចិត្តទុកដាក់បំផុត"។ ដូចនេះ ការវាយតម្លៃត្រូវគិតដល់ថាតើអ្នកប្រើប្រាស់ ខាងលើអាចត្រូវបានរំពឹងថានឹងទទួលរងឥទ្ធិពលលើការសម្រេចចិត្តផ្នែក សេដ្ឋកិច្ច។

**កំណត់សម្គាល់** មានបង្កប់នូវព័ត៌មានបន្ថែម លើព័ត៌មានដែលបានបង្ហាញនៅក្នុង របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ស្តីពីចំណូលផ្សេងៗ របាយការណ៍ចំណេញខាតដាច់ដោយឡែក (ប្រសិនបើបានបង្ហាញ) របាយការណ៍ស្តីពីការប្រែប្រួលលើមូលធនផ្ទាល់ និង របាយការណ៍លំហូរសាច់ប្រាក់។កំណត់សម្គាល់ផ្តល់នូវការពិពណ៌នា ឬ ធាតុតូចៗនៃធាតុនានាដែលបានបង្ហាញនៅក្នុងរបាយការណ៍ទាំងនោះហើយ និងព័ត៌មានអំពីធាតុនានា ដែលមិនបំពេញតាមលក្ខខណ្ឌ សម្រាប់ការទទួលស្គាល់នៅក្នុងរបាយការណ៍ទាំងនោះ។

**ចំណូលចំណាយបន្ទាប់បន្សំផ្សេងទៀត** មានធាតុនានានៃចំណូល និង ចំណាយ (រួមទាំងការចាត់ថ្នាក់ឡើងវិញលើការកែតម្រូវ) ដែលមិនត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត ដែលបានតម្រូវ ឬអនុញ្ញាតដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុដទៃទៀត។

សមាសធាតុនៃចំណូលចំណាយបន្ទាប់បន្សំដទៃទៀតរួមមាន :

(ក) ការប្រែប្រួលអតិរេកនៃការវាយតម្លៃឡើងវិញ (សូមមើលស្តង់ដាគណនេយ្យ ១៦ ស្តីពី *ទ្រព្យ រោងចក្រ និងបរិក្ខា* និងស្តង់ដា ៣៨ ស្តីពី *ទ្រព្យសកម្មអរូបិយ*)។

(ខ) ចំណេញ និងខាតជាក់ស្តែងលើផែនការអត្ថប្រយោជន៍ដែលបានកំណត់និងបានទទួលស្គាល់ ស្របតាមកថាខណ្ឌ ៩៣ (ក) នៃស្តង់ដាគណនេយ្យ ១៩ ស្តីពី *អត្ថប្រយោជន៍បុគ្គលិក*។

(គ) ចំណេញ និងខាត ដែលជាលទ្ធផល នៃការប្រែរបាយការណ៍ហិរញ្ញវត្ថុនៃប្រតិបត្តិការបរទេស (សូមមើលស្តង់ដាគណនេយ្យអន្តរជាតិ ២១ ស្តីពី *ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់បរទេស*)។

(ឃ) ចំណេញនិងខាតពីវិនិយោគទុនលើឧបករណ៍មូលធនផ្ទាល់ដែលបានវាស់វែងតាមតម្លៃទីផ្សារ តាមរយៈចំណូលចំណាយបន្ទាប់បន្សំដទៃទៀត ស្របតាមកថាខណ្ឌ ៥.៧.៥ នៃស្តង់ដាការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ស្តីពី *ឧបករណ៍ហិរញ្ញវត្ថុ*។

(ង) ផ្នែកនៃចំណេញ និងខាតដែលកើតមានលើឧបករណ៍ទប់ស្កាត់ហានិភ័យនៅ ក្នុងធាតុទប់ស្កាត់ លំហូរសាច់ប្រាក់ (សូមមើលស្តង់ដាគណនេយ្យអន្តរជាតិ ៣៩ ស្តីពី *ឧបករណ៍ហិរញ្ញវត្ថុ : ការទទួលស្គាល់និងការវាស់វែង*) ។

(ច) ចំនួនទឹកប្រាក់នៃការប្រែប្រួលនៃតម្លៃទីផ្សារ ដែលនាំឱ្យមានការប្រែប្រួលដល់ហានិភ័យឥណទាននៃបំណុលសម្រាប់រាល់បំណុលទាំងឡាយណា ដែលបានកំណត់តាមតម្លៃទីផ្សារតាមរយៈចំណេញ ឬខាត (សូមមើលកថាខណ្ឌទី ៥.៧.៧ នៃស្តង់ដា ៩)។

**ម្ចាស់ហ៊ុន** គឺជាអ្នកកាន់ឧបករណ៍ដែលបានចាត់ថ្នាក់ថាជាមូលធនផ្ទាល់។

**ចំណេញ ឬខាត** គឺជាចំនួនសរុប នៃចំណូលដកចំនួនសរុបនៃចំណាយ ដោយមិនគិតពីសមាសភាគនៃចំណូលបន្ទាប់បន្សំដទៃទៀតទេ។

**ការចាត់ថ្នាក់កំណែតម្រូវឡើងវិញ** គឺជាចំនួនទឹកប្រាក់ ដែលត្រូវបាន ចាត់ថ្នាក់ចូលក្នុងចំណេញ ឬខាតនាការិយបរិច្ឆេទបច្ចុប្បន្ន ដែលត្រូវបាន ទទួលស្គាល់នៅក្នុងចំណូលបន្ទាប់បន្សំដទៃទៀត នាការិយបរិច្ឆេទបច្ចុប្បន្ននិងនាការិយបរិច្ឆេទមុនៗ។

**ចំណូលបន្ទាប់បន្សំផ្សេងៗសរុប** គឺជាការប្រែប្រួលលើមូលធនផ្ទាល់ក្នុងការិយបរិច្ឆេទមួយ ដែលបណ្តាលមកពីប្រតិបត្តិការនិងព្រឹត្តិការណ៍នានា វាលែងតែការប្រែប្រួលទាំងនោះ បណ្តាលមកពីប្រតិបត្តិការជាមួយម្ចាស់មូលធនផ្ទាល់ក្នុងនាមជាម្ចាស់ហ៊ុន។

ចំណូលបន្ទាប់បន្សំផ្សេងៗសរុបរួមមានសមាសធាតុទាំងអស់នៃ “ចំណេញ ឬខាត” និងនៃ “ចំណូលបន្ទាប់បន្សំផ្សេងៗ”។

៨ ទោះបីជាស្តង់ដានេះប្រើវាក្យស័ព្ទ “ប្រាក់ចំណូលបន្ទាប់បន្សំផ្សេងៗទៀត” “ចំណេញឬខាត” និង “ប្រាក់ចំណូលបន្ទាប់បន្សំសរុប” ក៏ដោយក៏អង្គភាពអាចប្រើវាក្យស័ព្ទផ្សេងទៀត ដើម្បីពិពណ៌នាអំពីចំណូលសរុប ដរាបណា វាមានន័យច្បាស់លាស់។ ឧទាហរណ៍អង្គភាពអាចប្រើពាក្យ “ចំណេញសុទ្ធ” ដើម្បីពិពណ៌នាអំពីចំណេញឬខាត។

៨ក វាក្យស័ព្ទខាងក្រោមត្រូវបានបរិយាយនៅក្នុង ស្តង់ដាគណនេយ្យអន្តរជាតិ ៣២ស្តីពី*ឧបករណ៍ហិរញ្ញវត្ថុៈ ការដាក់បង្ហាញ* និងត្រូវបានប្រើក្នុងស្តង់ដានេះ ដែលមានន័យបញ្ជាក់នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ៣២ :

(ក) ឧបករណ៍ហិរញ្ញវត្ថុ ដែលអាចដាក់លក់បានដែលបានចាត់ថ្នាក់ជាឧបករណ៍មូលធនផ្ទាល់ (ដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ១៦ក និង ១៦ខ នៃស្តង់ដា

(ខ) ឧបករណ៍មួយដែលដាក់កាតព្វកិច្ចចំពោះអង្គភាព ឱ្យផ្តល់ដល់ភាគីផ្សេងទៀតនូវ សមាមាត្រតាមកម្រិតភាគហ៊ុននៃទ្រព្យសកម្មសរុបរបស់អង្គភាពតែស្តីពីការជម្រះបញ្ជី ហើយឧបករណ៍នោះត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធនផ្ទាល់ (ដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ១៦គ និង ១៦ឃ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣២)

## របាយការណ៍ហិរញ្ញវត្ថុ

### គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុ

៩ របាយការណ៍ហិរញ្ញវត្ថុគឺជាការដាក់បង្ហាញស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុដោយមានទម្រង់ច្បាស់លាស់ របស់អង្គភាពមួយ។ គោលបំណងរបស់របាយការណ៍ហិរញ្ញវត្ថុ គឺផ្តល់នូវព័ត៌មាន អំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាពដែលមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់នានា ក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។ របាយការណ៍ហិរញ្ញវត្ថុក៏បង្ហាញផងដែរអំពីលទ្ធផលនៃការគ្រប់គ្រងចាត់ចែងធនធានរបស់អ្នកគ្រប់គ្រងដែលទទួលបានការទុកចិត្ត។ ដើម្បីសម្រេចបាននូវគោលបំណងនេះ របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវព័ត៌- មាន អំពី :

(ក) ទ្រព្យសកម្មរបស់អង្គភាព។

(ខ) បំណុលរបស់អង្គភាព។

(គ) មូលធនផ្ទាល់របស់អង្គភាព។

(ឃ) ចំណូល ចំណាយ រួមទាំងចំណេញ ខាតរបស់អង្គភាព។

(ង) វិភាគទានផ្តល់ដោយម្ចាស់ហ៊ុននិងវិភាគទានដែលត្រូវផ្តល់ដល់ម្ចាស់ហ៊ុនក្នុងឋានៈជា ម្ចាស់ហ៊ុន និង

(ច) លំហូរសាច់ប្រាក់របស់អង្គភាព។

ព័ត៌មាននេះ រួមជាមួយព័ត៌មានផ្សេងៗទៀតនៅក្នុងកំណត់សម្គាល់ ជួយដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុក្នុងការព្យាករណ៍លំហូរសាច់ប្រាក់ របស់អង្គភាពនាពេលអនាគត ជាពិសេសការកំណត់ពេលវេលា និងភាពប្រាកដប្រជារបស់ពួកគេ។

## សំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ

១០ **សំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុមួយ មាន ៖**

**(ក) របាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ នាចុងការិយបរិច្ឆេទ**

**(ខ) របាយការណ៍ចំណូលបន្ទាប់បន្សំក្នុងកំឡុងការិយបរិច្ឆេទ**

**(គ) របាយការណ៍បម្រែបម្រួលមូលធនផ្ទាល់ក្នុង ការិយបរិច្ឆេទ**

**(ឃ) របាយការណ៍លំហូរសាច់ប្រាក់ក្នុងការិយបរិច្ឆេទ**

**(ង) កំណត់សម្គាល់ដែលមានសេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗនិង ព័ត៌មានពន្យល់ផ្សេងៗទៀត និង**

**(ច) របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាដើមការិយបរិច្ឆេទចុងក្រោយបំផុតដែលអាចប្រៀបធៀបបាននៅពេលដែលអង្គភាពមួយអនុវត្តគោលនយោបាយប្រតិសកម្ម ឬធ្វើការរាយការណ៍ប្រតិសកម្មអំពីធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ឬ នៅពេលដែល**

**អង្គភាពធ្វើ ចំណាត់ថ្នាក់ធាតុនានា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើងវិញ។**

**អង្គភាពអាចប្រើចំណងជើងផ្សេងពីចំណងជើងដែលប្រើក្នុងស្តង់ដានេះ។**

**១១ អង្គភាពត្រូវបង្ហាញដូចគ្នានេះដែរនូវគ្រប់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងសំណុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញ។**

១២ ដូចដែលបានអនុញ្ញាតដោយកថាខណ្ឌ ៨១ អង្គភាពអាចបង្ហាញសមាស-ធាតុនៃចំណេញ ឬខាត និងទាំងជាផ្នែកមួយនៃរបាយការណ៍តែមួយនៃចំណូលបន្ទាប់បន្សំ និងទាំងនៅក្នុងរបាយការណ៍លទ្ធផល ដាច់ដោយឡែក ។ នៅពេលដែលរបាយការណ៍លទ្ធផល ឬត្រូវបានបង្ហាញថាជាផ្នែកមួយនៃ សំណុំនៃរបាយការណ៍ហិរញ្ញវត្ថុពេញលេញ ហើយរបាយការណ៍លទ្ធផល ត្រូវបានដាក់បង្ហាញភ្លាមមុនពេលរបាយការណ៍ចំណូលបន្ទាប់បន្សំត្រូវបានបង្ហាញ។

១៣ នៅក្រៅរបាយការណ៍ហិរញ្ញវត្ថុ មានអង្គភាពភាគច្រើនបង្ហាញនូវរបាយ-ការណ៍ត្រួតពិនិត្យហិរញ្ញវត្ថុឡើងវិញ ដោយអ្នកគ្រប់គ្រងដែលរបាយការណ៍នោះពិពណ៌នា និងពន្យល់អំពីលក្ខណៈសំខាន់ៗនៃកិច្ចប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព ព្រមទាំងអំពីភាពមិនប្រាកដប្រជាចម្បងៗដែលអង្គភាពប្រឈម ។ របាយការណ៍នេះ អាចរួមបញ្ចូលនូវការត្រួតពិនិត្យលើ :

(ក) កត្តា និងឥទ្ធិពលសំខាន់ៗដែលកំណត់នូវកិច្ចប្រតិបត្តិហិរញ្ញវត្ថុរួមទាំងការប្រែប្រួលបរិស្ថានជុំវិញនានា ដែលអង្គភាពបានធ្វើក្នុងការឆ្លើយតបរបស់អង្គភាព ចំពោះការប្រែប្រួល និងឥទ្ធិពលរបស់វា ព្រមទាំងគោលនយោបាយរបស់អង្គភាព សម្រាប់វិនិយោគ ដើម្បី

រក្សានិងជម្រុញកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរួមទាំងគោលនយោបាយភាគលាភរបស់ខ្លួនផង។

(ខ) ប្រភពមូលនធិរបស់អង្គភាព ព្រមទាំងអត្រាបំណុលរបស់អង្គភាពធៀបជាមួយមូលធនផ្ទាល់ ដែលអង្គភាពចង់បាន និង

(គ) ធនធានរបស់អង្គភាពដែលមិនបានទទួលស្គាល់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ស្របតាមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

១៤ នៅក្រៅរបាយការណ៍ហិរញ្ញវត្ថុ អង្គភាពភាគច្រើនក៏បង្ហាញនូវការរាយ-កាណ៍និងរបាយការណ៍ ដូចជា របាយការណ៍បរិស្ថាន របាយការណ៍តម្លៃបន្ថែម ជាពិសេស ក្នុងឧស្សាហកម្មដែលកត្តា បរិស្ថានមានសារៈសំខាន់ និងនៅពេលដែលបុគ្គលិកត្រូវបានចាត់ទុកជា ក្រុមអ្នកប្រើប្រាស់ចម្បង។ ការរាយការណ៍ និងរបាយការណ៍ដែលបានបង្ហាញ ក្រៅរបាយការណ៍ហិរញ្ញវត្ថុមិនស្ថិតនៅក្នុងវិសាលភាពនៃស្តង់ដានេះទេ។

**ចរិកលក្ខណៈទូទៅ**

**ការបង្ហាញត្រឹមត្រូវ និង អនុលោមភាពទៅនឹងស្តង់ដា**

១៥ របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញឱ្យបានត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព ។ ការដាក់បង្ហាញដ៏ត្រឹមត្រូវតម្រូវឱ្យមានការបង្ហាដោយស្មោះត្រង់នូវ ផលប៉ះពាល់នៃប្រតិបត្តិការព្រឹត្តិការណ៍ដ៏ទៃទៀត ព្រមទាំងលក្ខខណ្ឌនានាស្របតាមនិយមន័យ និងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ដែលចែងនៅក្នុង*ក្របខ័ណ្ឌទស្សនទាននៃស្តង់ដា* ។ ដោយមានការលាតត្រដាងព័ត៌មានបន្ថែមបើមានការចាំបាច់ការអនុវត្ត តាមស្តង់ដា

**នេះត្រូវបានសន្មត់ថាមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើឱ្យ ការបង្ហាញមានភាពត្រឹមត្រូវ។**

**១៦ អង្គភាពដែលរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដានេះ ត្រូវបង្ហាញឱ្យច្បាស់ និងឥតលាក់លៀមអំពីអនុលោមភាពនេះ នៅក្នុងកំណត់សម្គាល់។ អង្គភាពមិនត្រូវពិពណ៌នាក្នុងរបាយការណ៍ហិរញ្ញវត្ថុថា អនុលោមតាមស្តង់ដានេះទេ វាលែងតែរបាយការណ៍ទាំងនោះស្របទាំង ស្រុងតាមការតម្រូវនានានៅក្នុងស្តង់ដា ។**

១៧ ក្នុងគ្រប់កាលទេសៈជាក់ស្តែងទាំងអស់ អង្គភាពបានធ្វើការបង្ហាញយ៉ាងត្រឹមត្រូវ ស្របតាមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដែលអាចអនុវត្តបាន។ការបង្ហាញយ៉ាងត្រឹមត្រូវក៏តម្រូវផងដែរឱ្យអង្គភាពៈ

(ក)ជ្រើសរើស និងអនុវត្តគោលនយោបាយគណនេយ្យ ស្របតាមស្តង់ដាគណនេយ្យ៨ ស្តីពី*គោលនយោបាយគណនេយ្យការប្រែប្រួលលើការប៉ាន់ស្មានគណនេយ្យ និងការភាន់ច្រឡំ* ។ ស្តង់ដាលេខ ៨ កំណត់នូវឋានានុក្រមនៃគោលការណ៍ណែនាំជាច់ណាត់ដែលអ្នកគ្រប់គ្រងបានពិចារណាក្នុងពេលដែលមិនមានស្តង់ដាណាអនុវត្តជាពិសេសចំពោះធាតុណាមួយ។

(ខ)បង្ហាញនូវព័ត៌មាន រួមបញ្ចូលទាំងគោលនយោបាយគណនេយ្យក្នុងន័យថាវាផ្តល់នូវព័ត៌មានពាក់ពន្ធ័ ដែលគួរឱ្យទុកចិត្ត អាចប្រៀបធៀបបាន និងអាចយល់បាន។

(គ)ផ្តល់នូវការលាតត្រដាងព័ត៌មានបន្ថែម នៅពេលដែលមានការតម្រូវ ជាពិសេសនៅក្នុងស្តង់ដាមានលក្ខណៈមិនគ្រប់គ្រាន់ដែលអាចឱ្យអ្នកប្រើប្រាស់ យល់ដឹងអំពីផលប៉ះពាល់ នៃប្រតិបត្តិការ

ពិសេសនៃព្រឹត្តិការណ៍ និងលក្ខខណ្ឌដ៏ទៃទៀតលើស្ថានភាព និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គភាព។

១៨ អង្គភាពមិនអាចកែតម្រូវគោលនយោបាយគណនេយ្យ មិនប្រក្រតីទាំងតាមរយៈការលាតត្រដាងព័ត៌មានអំពីគោលនយោបាយគណនេយ្យដែលបានប្រើនិងទាំងដោយកំណត់សម្គាល់ឬឧបករណ៍ពន្យល់បញ្ជាក់នានា ។

១៩ នៅក្នុងកាលទេសៈបំផុតខ្លះដែលអ្នកគ្រប់គ្រងសម្រេចថា អនុលោមភាពទៅនឹងការតម្រូវនៅក្នុង ស្តង់ដានៃការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ អាចនាំឱ្យមានការយល់ខុស បណ្តាលឱ្យមានទំនាស់ជាមួយ គោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុ កំណត់នៅក្នុង *ក្របខណ្ឌស្តង់ដា* អង្គភាពត្រូវងាកចេញពីការតម្រូវនោះ តាមលក្ខណៈដែលបានកំណត់នៅក្នុងកថាខណ្ឌ២០ ប្រសិនបើក្របខ័ណ្ឌ គតិយុត្តិពាក់ព័ន្ធតម្រូវឱ្យមានការងាកចេញនេះ ឬ បើមិនមានការហាមឃាត់ផ្សេងពីនេះទេ ។

២០ នៅពេលដែលអង្គភាពងាកចេញ មិនអនុវត្តតាមការតម្រូវនៃស្តង់ដា មួយស្របតាមកថាខណ្ឌ ១៩ អង្គភាពត្រូវលាតត្រដាងព័ត៌មាន :

(ក) ថាអ្នកគ្រប់គ្រងបានសន្និដ្ឋានថា របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញដោយត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព ។

(ខ) ថាអង្គភាពបានអនុលោមតាមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលអាចអនុវត្តបាន លើកលែងតែអង្គភាពបានងាកចេញមិនអនុវត្ត ការតម្រូវដោយឡែកណាមួយដើម្បីឱ្យការបង្ហាញមានលក្ខណៈត្រឹមត្រូវ ។

(គ) អំពីចំណងជើងនៃស្តង់ដា ដែលអង្គភាពងាកចេញមិនអនុវត្តតាម

លក្ខណៈនៃការងាកចេញមិនអនុវត្ត រួមទាំង ចំណាត់ការដែលស្តង់ដាដែលតម្រូវ ហេតុផលដែលចំណាត់ការនាំឱ្យមានការយល់ខុស ដូចនេះក្នុងកាលទេសៈ ដែលអាចនាំឱ្យមានទំនាស់ជាមួយគោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុ កំណត់នៅក្នុង *ក្របខណ្ឌស្តង់ដា* ព្រមទាំង ចំណាត់ការដែលបានអនុម័តយក ។

(ឃ) អំពីឥទ្ធិពលផ្នែកហិរញ្ញវត្ថុ ដោយការងាកចេញមិនអនុវត្តតាមស្តង់ដាលើធាតុនិមួយៗ ក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយ-បរិច្ឆេទរាយការណ៍នីមួយៗ ដែលអាចត្រូវបាន រាយការណ៍ថាអនុលោមតាមស្តង់ដា ។

២១ នៅពេលដែល អង្គភាពបានងាកចេញពីការអនុវត្តតាមការតម្រូវមួយនៃស្តង់ដាក្នុងការិយបរិច្ឆេទមុនមួយ ហើយដែលការងាកចេញនេះ មាន ឥទ្ធិពលដល់បរិមាណទឹកប្រាក់ ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទបច្ចុប្បន្នអង្គភាពត្រូវលាតត្រដាងព័ត៌មានដែលបានកំណត់នៅក្នុងកថាខណ្ឌ ២០ (គ) និង (ឃ) ។

២២ ជាឧទាហរណ៍ កថាខណ្ឌ២១អនុវត្តនៅពេលដែលអង្គភាពមួយបានងាកចេញមិនអនុវត្តតាមនាការិយបរិច្ឆេទ មុនពីការតម្រូវក្នុងស្តង់ដាសម្រាប់វាស់វែងនូវទ្រព្យសកម្ម ឬបំណុល និងដែលការងាកចេញនោះប៉ះពាល់ដល់ការវាស់វែងលើការប្រែប្រួលទ្រព្យសកម្មនិងបំណុលដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទបច្ចុប្បន្ន ។

២៣ ក្នុងកាលទេសៈដ៏កម្រខ្លះដែលអ្នកគ្រប់គ្រងបានសន្និដ្ឋានថាការអនុលោមតាមការតម្រូវក្នុងស្តង់ដា អាចមានការយល់ខុសខ្លាំង ដែលអាចនាំឱ្យ

មានទំនាស់ជាមួយគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុ កំណត់ក្នុង *ក្រប-ខណ្ឌ នៃស្តង់ដា* ប៉ុន្តែក្របខណ្ឌច្បាប់ពាក់ព័ន្ធហាមមិនឱ្យងាកចេញមិនអនុវត្តការតម្រូវនោះ អង្គភាពត្រូវកាត់បន្ថយជាអតិបរិមាតាមដែលអាចធ្វើទៅបាននូវទិដ្ឋភាពនាំឱ្យមានការយល់ខុសទាំងនោះ ដោយអនុលោមភាព និងធ្វើការលាតត្រដាងនូវ :

(ក) ចំណងជើងនៃស្តង់ដាដែលមានបញ្ហា លក្ខណៈនៃការតម្រូវព្រមទាំងហេតុផលដែលអ្នកគ្រប់គ្រងបានសន្និដ្ឋានថា អនុលោមតាមការតម្រូវក្នុងស្តង់ដា អាចមានការយល់ខុសខ្លាំង ក្នុងស្ថានភាពដែលអាចនាំឱ្យមានទំនាស់ ជាមួយគោលដៅ នៃរបាយការណ៍ហិរញ្ញវត្ថុកំណត់ក្នុង*ក្របខណ្ឌនៃខ្ទង់ដារ* និង

(ខ) ការកែតម្រូវនានា លើធាតុនីមួយៗក្នុង របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទនីមួយៗ ដែលអ្នកគ្រប់គ្រងសន្និដ្ឋានថាមានសារៈសំខាន់ដើម្បីធ្វើឱ្យការបង្ហាញ មានភាពត្រឹមត្រូវ។

២៤ សម្រាប់គោលបំណងដែលបានចែងក្នុងកថាខណ្ឌ ១៩ - ២៣ ធាតុ មួយនៃព័ត៌មាន អាចមានទំនាស់គ្នាជាមួយ គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុនៅពេលដែលធាតុនោះ មិនបង្ហាញយ៉ាងត្រឹមត្រូវនូវប្រតិបត្តិការព្រឹត្តិការណ៍ដទៃទៀត និងលក្ខខណ្ឌនានាដែល ធានាថាធាតុនោះនឹងបង្ហាញ ឬមិនរំពឹងយ៉ាងច្បាស់ថានឹងបង្ហាញហើយជាលទ្ធផលនៃធាតុនោះអាចជះឥទ្ធិពលលើ សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចដោយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ។ នៅពេលដែលវាយតម្លៃថាការអនុលោមតាមការតម្រូវ ពិសេសនៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិអាចនាំឱ្យយល់ខុស

ដែលការយល់ខុសនេះបណ្តាលឱ្យមានទំនាស់ជាមួយគោលបំណងរបស់របាយការណ៍ហិរញ្ញវត្ថុ ដែលចែងក្នុង*ក្របខណ្ឌស្តង់ដា* យ៉ាងណានោះ អ្នកគ្រប់គ្រង ត្រូវពិចារណា :

(ក) នូវមូលហេតុ ដែលគោលបំណង របស់របាយការណ៍ហិរញ្ញវត្ថុ សម្រេចមិនបាននៅក្នុងកាលទេសៈពិសេស និង

(ខ) កាលទេសៈរបស់អង្គភាព ខុសពីកាលទេសៈរបស់អង្គភាពដទៃទៀតដែលបានអនុលោមតាមការតម្រូវ។ ក្នុងកាលទេសៈដូចគ្នា ប្រសិនបើ អង្គភាពដទៃទៀតអនុលោមតាមការតម្រូវ វានឹងមានការសន្មត់ដែលច្រានចោលនូវអ្វីដែលថាអនុលោមភាពទៅនឹងការតម្រូវរបស់អង្គភាពនាំឱ្យមានការយល់ខុសហើយ ដែលនាំឱ្យមានទំនាស់ជាមួយគោលបំណងរបស់របាយការណ៍ហិរញ្ញវត្ថុដែលបានកំណត់នៅក្នុង *ក្របខណ្ឌស្តង់ដា*។

**និរន្តរភាព**

២៥ នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងត្រូវធ្វើការវាយតម្លៃលើលទ្ធភាពរបស់អង្គភាព ក្នុងការបន្តនិរន្តរភាព។ អង្គភាពត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាព វាលែងតែអ្នកគ្រប់គ្រងមានបំណងជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ធុរកិច្ចឬពុំមានជម្រើសពិតប្រាកដក្នុងការធ្វើដូចនេះ ។ ក្នុងការវាយតម្លៃនៅពេលដែលអ្នកគ្រប់គ្រងដឹងអំពី ភាពមិនប្រាកដប្រជាជាសារវ័ន្តទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា ដែលនាំឱ្យលែងមានការសង្ស័យលើលទ្ធភាពនៃការបន្តនិរន្តរភាព អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីភាពមិនប្រាកដប្រជាទាំងនោះ ។ នៅពេលដែលអង្គភាពមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយ

ឈរលើមូលដ្ឋាននិរន្តរភាពនោះទេ អង្គភាពត្រូវបង្ហាញអំពីករណីនេះ ព្រមទាំងលាតត្រដាង អំពីមូលដ្ឋាន ដែលអង្គភាពត្រូវយកមក រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងហេតុផលដែលអង្គភាពចាត់ទុកថាមិនមែនជានិរន្តរភាព ។

២៦ ក្នុងការវាយតម្លៃថាតើការសន្មត់អំពីនិរន្តរភាពមានភាពត្រឹមត្រូវ ឬយ៉ាងណានោះ អង្គភាពត្រូវគិតដល់ព័ត៌មានដែលអាចទទួលយកបានទាំងអស់អំពីអនាគតដែលយ៉ាងហោចណាស់១២ខែ ឬលើសពីនេះដោយគិតចាប់តាំងពី ការបញ្ចប់ការិយបរិច្ឆេទរាយការណ៍ ។ កម្រិតនៃការពិចារណាគឺអាស្រ័យលើហេតុការណ៍នៃករណីនិមួយៗ ។ ប្រសិនបើអង្គភាពធ្លាប់មានប្រតិបត្តិការអាចរកប្រាក់ចំណេញបាន ហើយរៀបចំទទួលបានធនធានអង្គភាពអាចធ្វើការសន្និដ្ឋានថា មូលដ្ឋាននិរន្តរភាព នៃគណនេយ្យមានភាពត្រឹមត្រូវ ដោយមិនចាំបាច់ មានការវិភាគលម្អិតណាមួយទេ។ ក្នុងករណីខ្លះ អ្នកគ្រប់គ្រងអាចត្រូវការពិចារណាលើកត្តានានាជាច្រើនទៀតដែលទាក់ទិននឹងលទ្ធភាពរកប្រាក់ចំណេញ បច្ចុប្បន្ន និង ដែលរំពឹងទុកទាក់ទិននឹងគម្រោងពេលសងបំណុល និងប្រភពសក្តានុពលនៃហិរញ្ញ-ប្បទានជំនួសមុននឹងអង្គភាពអាចពេញចិត្តខ្លួនឯងថា មូលដ្ឋាននិរន្តរភាពមានលក្ខណៈត្រឹមត្រូវ ។

### មូលដ្ឋានបង្គរនៃគណនេយ្យ

២៧ អង្គភាពត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយប្រើប្រាស់មូល-ដ្ឋានបង្គរនៃគណនេយ្យ លើកលែងតែព័ត៌មានអំពីលំហូរសាច់ប្រាក់ ។

២៨ នៅពេលដែលមូលដ្ឋានបង្គរនៃគណនេយ្យត្រូវបានប្រើប្រាស់ អង្គភាពត្រូវទទួលស្គាល់ធាតុនានាថាជាទ្រព្យសកម្ម បំណុល មូលធនផ្ទាល់ ចំណូល និង ចំណាយ (ធាតុនានានៃរបាយការណ៍ហិរញ្ញវត្ថុ ) នៅពេលដែលអង្គភាព បំពេញបាននូវនិយមន័យនិងលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ធាតុ ទាំងនោះនៅក្នុង*ក្របខណ្ឌស្តង់ដា**។

## ភាពជាសារវន្ត និង បូកសរុបរួម

២៩ អង្គភាពត្រូវបង្ហាញដាច់ដោយឡែកពីគ្នា នូវចំណាត់ថ្នាក់ជាសារវន្តនៃធាតុប្រហាក់ប្រហែលនានា។ អង្គភាពត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវធាតុនានាតាមប្រភេទ និងតួនាទី នៅពេលដែលធាតុទាំងនោះមិនមានភាពជាសារវន្ត ។

៣០ របាយការណ៍ហិរញ្ញវត្ថុ ដែលបានមកពីដំណើរការប្រតិបត្តិការច្រើន ឬពីព្រឹត្តិការណ៍ដទៃទៀត ដែលបានសរុបរួមជាថ្នាក់នានា តាមប្រភេទ ឬនាទីរបស់វា។ ដំណាក់កាលចុងក្រោយនៃការរួមបញ្ចូលនិងការធ្វើចំណាត់ថ្នាក់ គឺជាការបង្ហាញនូវទិន្នន័យ ដែលបានរួមបញ្ចូល និងបានចាត់ថ្នាក់ហើយដែលបង្កើតបានជាជួរនៃធាតុក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើធាតុពាក់ព័ន្ធមួយ ដែលមានលក្ខណៈមិនសារវន្ត វាត្រូវបញ្ចូលជាមួយធាតុផ្សេងៗទៀត ទាំងនៅក្នុងរបាយការណ៍នោះ និងទាំងក្នុង កំណត់សម្គាល់។ធាតុដែលមានលក្ខណៈមិនសារវន្តគ្រប់គ្រាន់អាចធ្វើការបង្ហាញដាច់ដោយឡែក នៅក្នុងកំណត់សម្គាល់ ដើម្បីធានាដល់ការបង្ហាញដាច់ដោយឡែកក្នុងរបាយការណ៍ទាំងនោះ ។

៣១ អង្គភាពមិនចាំបាច់លាតត្រដាងព័ត៌មានដោយឡែកមួយ តាមការតម្រូវរបស់ស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិទេ ប្រសិនបើព័ត៌មានទាំងនោះមិនមានលក្ខណៈជាសារវន្ត ។

**ការកាត់កង**

**៣២ អង្គភាពមិនត្រូវធ្វើការកាត់កងរវាងទ្រព្យសកម្ម ជាមួយនឹងបំណុល ឬរវាងចំណូលនិងចំណាយនោះទេ វាលែងតែ មានការតម្រូវ ឬអនុញ្ញាត ដោយស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ។**

៣៣ អង្គភាពរាយការណ៍ដាច់ដោយឡែកពីគ្នារវាងទ្រព្យសកម្មនិងបំណុល និងរវាងចំណូលនិងចំណាយ។ ការកាត់កងក្នុងរបាយការណ៍ចំណូលសរុបរួម ឬក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ ឬនៅក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែក (ប្រសិនបើត្រូវបានបង្ហាញ) នាំឱ្យបន្ថយនូវ លទ្ធភាពរបស់អ្នកប្រើប្រាស់ទាំងនៅក្នុងការយល់ដឹងអំពីប្រតិបត្តិការអំពីព្រឹត្តិការណ៍ និងលក្ខខណ្ឌផ្សេងៗ និងទាំងនៅក្នុងការវាយតម្លៃលំហូរសាច់ប្រាក់របស់អង្គភាពនាពេលអនាគត លើកលែងតែនៅពេលដែល ការកាត់កងនោះវាបង្ហាញនូវសារជាតិនៃប្រតិបត្តិការឬព្រឹត្តិការណ៍ដទៃទៀត។ ឧទាហរណ៍ ការវាស់វែងទ្រព្យសកម្មសុទ្ធដែលបានមកពីវិភាជន៍នៃការវាយតម្លៃវិភាជន៍ដោយភាពហួសសម័យរបស់សន្និធិ និងវិភាជន៍លើបំណុលសង្ស័យរបស់គណនីអតិថិជន មិនត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងឡើយ។

៣៤ ស្តង់ដាគណនេយ្យអន្តរជាតិ ១៨ ស្តីពី *ចំណូល* បានកំណត់និយមន័យ អំពីចំណូល និងតម្រូវឱ្យអង្គភាពវាស់វែងនូវចំណូលនោះតាមតម្លៃទីផ្សារ នៃតម្លៃតបស្នងដែលបានទទួល ឬដែលអាចទទួលបាន ដោយគិតដល់

បរិមាណទឹកប្រាក់ នៃអប្បហារពាណិជ្ជកម្ម ព្រមទាំងបរិមាណទឹកប្រាក់ដែលបានបង្វិលសងដែលអង្គភាពអនុញ្ញាត ។ ក្នុងសកម្មភាពអាជីវកម្មជាធម្មតារបស់ខ្លួន អង្គភាពធ្វើប្រតិបត្តិការផ្សេងៗទៀត ដែលមិនប្រមូលចំណូលបាន ប៉ុន្តែវាកើតឡើងដោយចៃដន្យហើយនាំប៉ះពាល់ដល់សកម្មភាព ប្រមូលចំណូលចម្បង។ អង្គភាពត្រូវបង្ហាញលទ្ធផលនៃប្រតិបត្តិការទាំងនោះនៅពេល ដែលការបង្ហាញនោះស្តែងឡើង នូវសារជាតិរបស់ប្រតិបត្តិការ ឬព្រឹត្តិការណ៍ផ្សេងៗ ដោយទូទាត់ចំណូលជាមួយចំណាយពាក់ព័ន្ធដែលកើតមានពីប្រតិបត្តិការតែមួយ។ ឧទាហរណ៍ដូចជា :

(ក)អង្គភាពបង្ហាញនូវប្រាក់ចំណេញ និងការខាតបង់ លើការលក់បញ្ចេញចោលទ្រព្យសកម្មរយៈពេលវែង រួមបញ្ចូលទាំងវិនិយោគ និងទ្រព្យសកម្មប្រតិបត្តិការ ដោយធ្វើការកាត់កងពីចំណូលពីការលក់បញ្ចេញចោលនូវតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្ម និងចំណាយពាក់ព័ន្ធដទៃទៀត និង

(ខ)អង្គភាពអាកាត់នូវចំណាយពាក់ព័ន្ធនឹងសំវិធានធន ដែលត្រូវបានទទួលស្គាល់ដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ ៣៧ ស្តីពី*សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* និងអាចកាត់សងមកវិញ តាមកិច្ចសន្យាជាមួយតិយជន (ដូចជាកិច្ចសន្យាធានារបស់អ្នកផ្គត់ផ្គង់) នូវសំណងដែលពាក់ព័ន្ធ។

៣៥ បន្ថែមលើសពីនេះទៀត អង្គភាពត្រូវបង្ហាញដោយផ្អែកលើចំណេញ និងការខាតបង់សុទ្ធដែលបណ្តាលមកពីក្រុមនៃប្រតិបត្តិការប្រហាក់ប្រហែលគ្នា។ ឧទាហរណ៍ ប្រាក់ចំណេញ និងការខាតបង់ពីអត្រាប្តូរប្រាក់បរទេស ឬចំណេញ ឬការខាតបង់ ដែលកើតពីឧបករណ៍ហិរញ្ញវត្ថុដែលបានដាក់

លក់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏អង្គភាពត្រូវបង្ហាញប្រាក់ចំណេញ និងខាតនេះដាច់ដោយឡែក ប្រសិនបើវាមានលក្ខណៈជាសារវន្ត។

ប្រេកង់នៃការរាយការណ៍

៣៦ អង្គភាពត្រូវបង្ហាញនូវ សំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ (រួមទាំងព័ត៌មានប្រៀបធៀប) យ៉ាងហោចណាស់មួយឆ្នាំម្តង។ នៅពេល អង្គភាពផ្លាស់ប្តូរការបញ្ចប់នៃការិយបរិច្ឆេទរាយការណ៍របស់ខ្លួន និងបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទច្រើនជាង ឬ តិចជាងមួយឆ្នាំ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោមបន្ថែមលើការិយបរិច្ឆេទតាមរបាយការណ៍ហិរញ្ញវត្ថុ:

(ក) មូលហេតុក្នុងការប្រើការិយបរិច្ឆេទលើស ឬតិចជាមួយឆ្នាំ និង

(ខ) ការណ៍ដែលបរិមាណសាច់ប្រាក់ដែលបង្ហាញនៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុមានលក្ខណៈមិនអាចប្រៀបធៀបបាន ទាំងស្រុង។

៣៧ អង្គភាពតែងតែរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទមួយឆ្នាំ។ ទោះបីជាយ៉ាងណា សម្រាប់ការអនុវត្តជាក់ស្តែងអង្គភាពខ្លះចង់រៀបចំរបាយការណ៍នេះសម្រាប់ការិយបរិច្ឆេទ ៥២ សប្តាហ៍ ។ ស្តង់ដានេះមិនច្រានចោលការអនុវត្តបែបនេះឡើយ ។

<u>ព័ត៌មានប្រៀបធៀប</u>

៣៨ វាលែងតែនៅពេលដែលស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិអនុញ្ញាត ឬតម្រូវផ្សេងពីនេះ អង្គភាពត្រូវលាតត្រដាងព័ត៌មាន ប្រៀបធៀប ដោយយោងតាមការិយបរិច្ឆេទមុនៗ នូវរាល់បរិមាណទឹកប្រាក់ដែល

**បានរាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុ នាការិយបរិច្ឆេទបច្ចុប្បន្ន ។ អង្គភាពត្រូវបញ្ចូលព័ត៌មានប្រៀបធៀបតាមបែបពិពណ៌នា នៅពេលដែលព័ត៌មាននោះទាក់ទិននឹង ការយល់ដឹងលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។**

៣៩ អង្គភាពដែលលាតត្រដាងព័ត៌មានប្រៀបធៀប យ៉ាងហោចណាស់ត្រូវបង្ហាញរបាយការណ៍ស្តីពី ស្ថានភាពហិរញ្ញវត្ថុចំនួនពីររបាយការណ៍ផ្សេងទៀតចំនួនពីរសម្រាប់របាយការណ៍និមួយៗព្រមទាំងកំណត់សម្គាល់នានាដែលពាក់ព័ន្ធ។នៅពេលដែល អង្គភាពអនុវត្តប្រតិសកម្មនូវគោលនយោបាយគណនេយ្យ ឬធ្វើការរាយការណ៍ឡើងវិញដោយប្រតិសកម្មលើធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ឬនៅពេលដែលអង្គភាពធ្វើចំណាត់ថ្នាក់ឡើងវិញនូវធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន យ៉ាងហោចណាស់ អង្គភាពត្រូវបង្ហាញ របាយការណ៍ស្តីពី ស្ថានភាពហិរញ្ញវត្ថុចំនួនបី របាយការណ៍ផ្សេងៗទៀតចំនួនពីរសម្រាប់របាយការណ៍និមួយៗ និងកំណត់សម្គាល់នានាដែលពាក់ព័ន្ធ។ អង្គភាពបង្ហាញរបាយការណ៍ ស្តីពីស្ថានភាពហិរញ្ញវត្ថុ :

(ក) នាចុងការិយបរិច្ឆេទបច្ចុប្បន្ន

(ខ) នាចុងការិយបរិច្ឆេទមុនៗ (ដែលដូចគ្នាទៅនឹង ការចាប់ផ្តើមការិយបរិច្ឆេទបច្ចុប្បន្ន) និង

(គ) ដើមការិយបរិច្ឆេទដែលអាចប្រៀបធៀបបាន ចុងក្រោយបង្អស់។

៤០ ក្នុងករណីខ្លះ ព័ត៌មានលម្អិតដែលមានផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទមុនៗ នៅតែបន្តពាក់ព័ន្ធជាមួយការិយបរិច្ឆេទបច្ចុប្បន្ន។ ឧទាហរណ៍ អង្គភាពមួយលាតត្រដាងយ៉ាងលម្អិតអំពីវិវាទខាងផ្លូវច្បាប់

នាការិយបរិច្ឆេទបច្ចុប្បន្ន ដែលលទ្ធផលរបស់វាមានលក្ខណៈមិនប្រាកដប្រជានាចុងការិយបរិច្ឆេទរាយការណ៍មុនថ្មីៗ ហើយដែលមិនទាន់ត្រូវបានដោះស្រាយនៅឡើយ។ អ្នកប្រើប្រាស់អាស្រ័យផលពីព័ត៌មានដែលភាពមិនប្រាកដប្រជាដែលបានកើតមាននាចុងការិយបរិច្ឆេទរាយការណ៍មុនថ្មីៗ និងអំពីដំណាក់កាលនានា ដែលបានធ្វើឡើងក្នុងកំឡុងការិយ-បរិច្ឆេទ ដើម្បីដោះស្រាយភាពមិនប្រាកដប្រជា។

៤១ **នៅពេលដែលអង្គភាពផ្លាស់ប្តូរនូវការបង្ហាញឬការចាត់ថ្នាក់ធាតុនានា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវធ្វើការចាត់ថ្នាក់ឡើងវិញនូវបរិមាណទឹកប្រាក់ប្រៀបធៀប វាលែងតែការចាត់ថ្នាក់ឡើងវិញនោះ មិនអាចធ្វើទៅបាន ។ នៅពេលដែលអង្គភាពធ្វើការចាត់ថ្នាក់ឡើងវិញនូវបរិមាណទឹកប្រាក់ប្រៀបធៀប អង្គភាពត្រូវលាតត្រដាងព័ត៌មាន :**

**(ក) ចរិកលក្ខណៈនៃការចាត់ថ្នាក់ឡើងវិញ**

**(ខ) បរិមាណនៃធាតុនីមួយៗ ឬថ្នាក់នៃធាតុនានាដែលត្រូវបានចាត់ថ្នាក់ឡើងវិញ និង**

**(គ) ហេតុផលដែលនាំឱ្យមានការចាត់ថ្នាក់ឡើងវិញ។**

៤២ **នៅពេលដែលការអនុវត្តក្នុងការចាត់ថ្នាក់ឡើងវិញលើបរិមាណទឹកប្រាក់ប្រៀបធៀបមិនអាចធ្វើ ទៅបាន អង្គភាពត្រូវលាតត្រដាងនូវ :**

**(ក) ហេតុផលដែលនាំឱ្យមិនអាចធ្វើការចាត់ថ្នាក់ឡើងវិញបាន និង**

**(ខ) ចរិកលក្ខណៈនៃការកែតម្រូវ ដែលអាចត្រូវបានធ្វើឡើងបើបរិមាណទឹកប្រាក់ត្រូវបានចាត់ថ្នាក់ឡើងវិញ។**

៤៣ ការធ្វើឱ្យប្រសើរឡើងនូវភាពដែលអាចប្រៀបធៀបគ្នាបាននៃព័ត៌មានក្នុងចន្លោះការិយបរិច្ឆេទ ជួយអ្នកប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែក

សេដ្ឋកិច្ច ពិសេសអនុញ្ញាតឱ្យគេអាចវាយតម្លៃលើ និន្នាការនៃព័ត៌មានហិរញ្ញវត្ថុសម្រាប់គោលបំណងព្យាករណ៍។ក្នុងកាលទេសៈខ្លះ គេមិនអាចធ្វើការចាត់ថ្នាក់ឡើងវិញបាននូវព័ត៌មានប្រៀបធៀប សម្រាប់ការិយបរិច្ឆេទមុនដោយឡែកណាមួយ ដើម្បីអាចប្រៀបធៀបបានជាមួយការិយបរិច្ឆេទបច្ចុប្បន្ន។ ឧទាហរណ៍ អង្គភាពមួយ អាចមិនបានប្រមូលទិន្នន័យដែលមានក្នុងការិយបរិច្ឆេទមុនៗ ដែលអាចឱ្យគេប្រើ ដើម្បីធ្វើការចាត់ថ្នាក់ឡើងវិញ ហើយអង្គភាពមិនអាចបង្កើតឡើងវិញនូវព័ត៌មាននោះបានទេ។

៤៤ ស្តង់ដាគណនេយ្យអន្តរជាតិ ៨ កំណត់នូវការកែតម្រូវលើព័ត៌មានប្រៀបធៀបដែលតម្រូវ នៅពេលដែលអង្គភាពផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ឬកែនូវកំហុសឆ្គង។

### សង្គតភាពនៃការបង្ហាញ

៤៥ អង្គភាពត្រូវរក្សាការបង្ហាញនិងការចាត់ថ្នាក់ធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពីការិយបរិច្ឆេទ មួយទៅការិយបរិច្ឆេទមួយទៀត វាលែងតែ :

(ក) ដោយសារតែមានការប្រែប្រួលខ្លាំងលើចរិកលក្ខណៈនៃប្រតិបត្តិការរបស់អង្គភាព ឬមានការសើរើឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន វាមានភាពប្រាកដច្បាស់ថា ការបង្ហាញ ឬការចាត់ថ្នាក់ផ្សេងទៀតមានលក្ខណៈត្រឹមត្រូវជាង ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសយក និងការអនុវត្តគោលនយោបាយគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិ ៨។ ឬ

(ខ) ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិតម្រូវឱ្យមានការប្រែប្រួលលើការបង្ហាញ។

៤៦ ជាឧទាហរណ៍ ការទិញចូលឬការលក់ចោលចាំបាច់មួយឬការត្រួតពិនិត្យឡើងវិញលើការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុអាចស្នើឡើងថារបាយការណ៍ហិរញ្ញវត្ថុត្រូវតែបានបង្ហាញផ្សេងពីគ្នា។ អង្គភាពមួយផ្លាស់ប្តូរការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន តែនៅពេលដែលការបង្ហាញបានកែប្រែនោះផ្តល់ព័ត៌មាន ដែលអាចទុកចិត្តបាន និងដែលមានការពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ និងដែលរចនាសម្ព័ន្ធកែប្រែនោះអាចនៅបន្តធ្វើ ដូចនេះភាពដែលអាចប្រៀបធៀបបានគឺមិនត្រឹមត្រូវទេ។ នៅពេលដែលធ្វើការផ្លាស់ប្តូរលើការបង្ហាញដូចនេះ អង្គភាពត្រូវធ្វើការចាត់ថ្នាក់ឡើងវិញនូវព័ត៌មានប្រៀបធៀបរបស់ខ្លួន ស្របតាមកថាខណ្ឌ ៤១ និង ៤២។

**រចនាសម្ព័ន្ធ និងមាតិកា**

---

## សេចក្តីផ្តើម

**Introduction**

៤៧ ស្តង់ដានេះ តម្រូវឱ្យមានការលាតត្រដាងព័ត៌មាន ជាពិសេសនៅក្នុងរបាយការណ៍ ស្តីពីស្ថានភាពហិរញ្ញវត្ថុ ឬអំពីចំណូលបន្ទាប់បន្សំនៅក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែក(ប្រសិនត្រូវបានបង្ហាញ) ឬនៅក្នុងរបាយការណ៍ នៃការប្រែប្រួលលើមូលធនផ្ទាល់ ព្រមទាំងតម្រូវឱ្យលាតត្រដាងព័ត៌មានអំពីធាតុពាក់ព័ន្ធដទៃទៀត ទាំងនៅក្នុងរបាយការណ៍ខាងលើ និងទាំងក្នុងកំណត់សម្គាល់។ ស្តង់ដាគណនេយ្យអន្តរជាតិ ៧ ស្តីពី *របាយការណ៍លំហូរសាច់ប្រាក់* កំណត់នូវ តម្រូវការសម្រាប់ការបង្ហាញព័ត៌មានអំពីលំហូរសាច់ប្រាក់។

៤៨ ជូនកាល ស្តង់ដានេះប្រើពាក្យស័ព្ទ "ការលាតត្រដាងព័ត៌មាន" ក្នុងន័យទូលាយ ដោយរួមទាំងធាតុនានា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផង។ ស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដទៃទៀត ក៏តម្រូវ ឱ្យមានការលាតត្រដាងព័ត៌មានផងដែរ។ លើកលែងតែមានការបញ្ជាក់ ផ្ទុយនៅកន្លែងណាមួយនៅក្នុងស្តង់ដានេះ ឬនៅក្នុងស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដទៃទៀត ការលាតត្រដាងព័ត៌មានបែបនេះ ត្រូវបានធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។\

**ការកំណត់អត្តសញ្ញាណនៃរបាយការណ៍ហិរញ្ញវត្ថុ**

**៤៩ អង្គភាពត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីរបាយការណ៍ហិរញ្ញវត្ថុ និងបែងចែករបាយការណ៍នោះឱ្យដាច់ ពីព័ត៌មានដទៃទៀតនៅក្នុងឯកសារតែមួយដែលបានបោះផ្សាយ។**

៥០ ស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ អនុវត្តចំពោះតែរបាយការណ៍ហិរញ្ញវត្ថុ និងមិនចាំបាច់អនុវត្តចំពោះព័ត៌មានផ្សេងទៀតដែលបានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ សំណុំឯកសារគតិយុត្ត ឬឯកសារផ្សេងទៀត។ ដូចនេះវាមានការចាំបាច់ណាស់ដែលថាអ្នកប្រើប្រាស់អាចបែងចែកឱ្យដាច់នូវព័ត៌មាន ដែលបានរៀបចំឡើងដោយប្រើស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ពីព័ត៌មានផ្សេងទៀតដែលអាចមានប្រយោជន៍ដល់អ្នកប្រើប្រាស់ ប៉ុន្តែមិនមែនជាកម្មវត្ថុនៃការតម្រូវទាំងនោះទេ។

**៥១ អង្គភាពត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីរបាយការណ៍ហិរញ្ញវត្ថុនិមួយៗ និងអំពីកំណត់សម្គាល់ ។ លើសពីនេះទៀត អង្គភាពត្រូវដាក់បង្ហាញនូវ**

ព័ត៌មានដោយជាក់ស្តែងដូចខាងក្រោម ព្រមទាំងដាក់បង្ហាញឡើងវិញទៀត នូវព័ត៌មាននោះបើមានការចាំបាច់ត្រូវបង្ហាញ ដើម្បីអាចយល់បាន :

(ក) នាមករណ៍របស់អង្គភាពរាយការណ៍ ឬមធ្យោបាយផ្សេងទៀតដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនព្រមទាំងការប្រែប្រួលលើព័ត៌មាននានា ដោយគិតចាប់ពីចុងការិយបរិច្ឆេទរាយការណ៍មុនៗ។

(ខ) របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយ ឬ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមនៃអង្គភាពទាំងអស់។

(គ) កាលបរិច្ឆេទនៃចុងការិយបរិច្ឆេទរាយការណ៍ ឬការិយបរិច្ឆេទ នៃសំណុំរបាយការណ៍ហិរញ្ញវត្ថុ ឬកំណត់សម្គាល់។

(ឃ) រូបិយបណ្ណដែលដាក់បង្ហាញ ដូចដែលបានកំណត់នៅ ក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ២១ និង

(ង) កម្រិតនៃការកាត់ខ្ទង់ក្រោយក្បៀសដែលបានប្រើប្រាស់ក្នុងការបង្ហាញបរិមាណទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៥២ អង្គភាពបំពេញបានតាមការតម្រូវក្នុង កថាខ័ណ្ឌ ៥១ ដោយបង្ហាញនូវចំណងជើងត្រឹមត្រូវលើទំព័រនានាលើរបាយការណ៍ លើកំណត់សម្គាល់លើកូលោននានា ពិត័មានដែលស្រដៀងគ្នានេះ។ គេត្រូវការចាំបាច់ នូវការសម្រេចចិត្តក្នុងការកំណត់នូវ មធ្យោបាយដ៏ល្អបំផុតក្នុងការបង្ហាញនូវព័ត៌មានបែបនោះ។ ឧទាហរណ៍ ដូចជានៅពេលដែលអង្គភាពបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ តាមប្រព័ន្ធអេឡិចត្រូនិច ជានិច្ចកាលមិនត្រូវប្រើប្រាស់ទំព័រដាច់ពីគ្នានោះទេ ដូច្នេះហើយអង្គភាពបង្ហាញនូវ ធាតុនានាខាងលើ ដើម្បីធានាថាព័ត៌មានដែលបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចយល់បាន។

៥៣ អង្គភាពតែងតែធ្វើយ៉ាងណាឱ្យរបាយការណ៍ហិរញ្ញវត្ថុកាន់តែមានភាពអាចយល់ដឹងបាន ដោយធ្វើការបង្ហាញនូវព័ត៌មានជាឯកតារូបិយប័ណ្ណដោយខ្ទង់ពាន់ ឬខ្ទង់លាន។ ការធ្វើបែបនេះអាចទទួលយកបាន ដរាបណា អង្គភាពលាតត្រដាងព័ត៌មានអំពីកម្រិតនៃការកាត់ខ្ទង់ក្រោយក្បៀស និងដរាបណាអង្គភាពមិនលុបចោលព័ត៌មានដែលមានលក្ខណៈជាសារវន្ត។

## របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ

### ព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ

៥៤ យ៉ាងហោចណាស់របាយការណ៍ ស្តីពីស្ថានភាពហិរញ្ញវត្ថុ ត្រូវបញ្ចូលនូវធាតុនានាដែលបង្ហាញនូវបរិមាណទឹកប្រាក់ដូចខាងក្រោម :

(ក) ទ្រព្យ រោងចក្រ និងបរិក្ខា

(ខ) ទ្រព្យវិនិយោគ

(គ) ទ្រព្យសកម្មអរូបិយ

(ឃ) ទ្រព្យសកម្មហិរញ្ញវត្ថុ(មិនរាប់បញ្ចូលបរិមាណទឹកប្រាក់ដែលបានបង្ហាញនៅក្នុងចំណុច (ង) (ជ) (ឈ) )

(ង)វិនិយោគដែលបានកត់ត្រាដោយប្រើវិធីសាស្រ្តមូលធនផ្ទាល់

(ច) ទ្រព្យសកម្មជីវសាស្រ្ត

(ឆ) សន្និធិ

(ជ) ចំណូល និងគណនីត្រូវទទួលដទៃទៀត

(ឈ) សាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែល

(ញ) ចំនួនសរុបនៃទ្រព្យសកម្មដែលបានរក្សាទុកសម្រាប់លក់ ឬទ្រព្យសកម្មដែលបានបញ្ចូលក្នុងក្រុមទ្រព្យត្រូវលក់បញ្ចេញចោលដែលបានចាត់ថាទុកសម្រាប់លក់ ស្របតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៥ ស្តីពី *ទ្រព្យសកម្មរយៈពេលវែងដែលទុកសម្រាប់លក់និងប្រតិបត្តិមិនបន្ត*។

(ដ) ចំណាយនិងគណនីអ្នកផ្គត់ផ្គង់ដទៃទៀត

(ឋ) សំវិធានធន

(ឌ) បំណុលហិរញ្ញវត្ថុ (មិនរាប់បញ្ចូលបរិមាណទឹកប្រាក់ដែលបង្ហាញតាមចំណុច (ដ) និង (ឋ)

(ឈ្ប) បំណុល និងទ្រព្យសកម្មសម្រាប់បង់ពន្ធ ដូចដែលបានកំណត់ក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ១២ ស្តីពី *ពន្ធលើប្រាក់ចំណូល*។

(ន) បំណុលពន្ធពន្យា និងទ្រព្យសកម្មជាពន្ធពន្យា ដូចដែលបានកំណត់ក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ១២។

(ត) បំណុលនានា ដែលបានបញ្ចូលក្នុងក្រុមសម្រាប់ការលក់បញ្ចេញចោលហើយបានចាត់ថ្នាក់ថាជា បំណុលទុកសម្រាប់លក់ទៅវិញ ស្របតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៥

(ថ) អត្ថប្រយោជន៍ដែលមិនបានត្រួតពិនិត្យ ដែលបានបង្ហាញនៅក្នុង មូលធនផ្ទាល់ និង

(ទ) មូលធនដែលបានបោះផ្សាយ និងទុនបម្រុងដែលអាចផ្តល់ជូនដល់ម្ចាស់ហ៊ុននៃក្រុមហ៊ុនមេ។

៥៥ អង្គភាពត្រូវបង្ហាញនូវធាតុពាក់ព័ន្ធនានាបន្ថែម ចំណងជើងធំ និងចំណងជើងរងនៅក្នុងរបាយការណ៍ ស្តីពីស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលការបង្ហាញនោះមានការពាក់ព័ន្ធនឹងការយល់ដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។

៥៦ នៅពេលដែលអង្គភាពបង្ហាញអំពីទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង ព្រមទាំងបំណុលរយៈពេលខ្លី និងបំណុលរយៈពេលវែង ដោយធ្វើការចាត់ថ្នាក់ដាច់ដោយឡែកពីគ្នា នៅក្នុងរបាយការណ៍ ស្តីពីស្ថានភាពហិរញ្ញវត្ថុ អង្គភាពមិនត្រូវចាត់ថ្នាក់ទ្រព្យសកម្ម (បំណុល) ជាពន្ធពន្យា ថាជាទ្រព្យសកម្ម(បំណុល)រយៈពេលខ្លីនោះទេ។

៥៧ ស្តង់ដានេះ មិនពិពណ៌នាអំពីលំដាប់លំដោយ ឬទម្រង់ដែលអង្គភាព ត្រូវបង្ហាញធាតុនានានោះទេ។ កថាខណ្ឌ ៥៤ គ្រាន់តែរាយបញ្ជីនូវធាតុ នានាជាធម្មតា ដែលមានលក្ខណៈខុសគ្នានូវប្រភេទនិងតួនាទី ដើម្បីធានា ដល់ការបង្ហាញដាច់ដោយឡែកក្នុងរបាយការណ៍ ស្តីពីស្ថានភាពហិរញ្ញវត្ថុ។ បន្ថែមលើសពីនេះទៀត :

(ក) ធាតុពាក់ព័ន្ធនានា ត្រូវបានបញ្ចូលគ្នា នៅពេលដែលទំហំ ប្រភេទ ឬតួនាទីរបស់ធាតុមួយឬចំនួនសរុបនៃធាតុប្រហាក់ប្រហែលនានា ត្រូវបានធ្វើឱ្យការបង្ហាញដាច់ដោយឡែក គឺដើម្បីធ្វើឱ្យគេយល់ដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព និង

(ខ) ការពិពណ៌នាដែលបានប្រើ និងការរៀបតាមលំដាប់លំដោយនៃធាតុ ឬចំនួនសរុបនៃធាតុប្រហាក់ប្រហែល អាចត្រូវបានកែប្រែស្របតាមប្រភេទអង្គភាពនិងប្រតិបត្តិការរបស់វា ដែលវាទាំងនោះផ្តល់នូវព័ត៌មាន ធ្វើឱ្យគេយល់ដឹងអំពី ស្ថានភាពហិរញ្ញវត្ថុ របស់

អង្គភាព។ ឧទាហរណ៍ ដូចជាស្ថាប័នហិរញ្ញវត្ថុមួយ អាចកែតម្រូវនូវការពិពណ៌នាខាងលើ ដើម្បីផ្តល់ព័ត៌មាន ដែលពាក់ព័ន្ធដល់ប្រតិបត្តិការរបស់អង្គភាពមួយ។

៥៨ អង្គភាពអាចធ្វើការសម្រេចចិត្ត អំពីថាតើត្រូវបង្ហាញនូវ ធាតុនានាបន្ថែមដាច់ដោយឡែកឬយ៉ាងណាដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃលើ :

(ក) ចរិកលក្ខណៈនិងសន្ទនីយភាពនៃទ្រព្យសកម្ម

(ខ) តួនាទីរបស់ទ្រព្យសកម្មនៅក្នុងអង្គភាព និង

(គ) បរិមាណ ប្រភេទ និងកាលកំណត់នៃបំណុល ។

៥៩ ការប្រើប្រាស់នូវមូលដ្ឋាននៃការវាស់វែងខុសគ្នាសម្រាប់ការចាត់ថ្នាក់ខុសគ្នានៃទ្រព្យសកម្ម ស្នើថា ប្រភេទ ឬតួនាទីរបស់ទ្រព្យសកម្មខុសគ្នា ហើយស្នើថា អង្គភាពបង្ហាញទ្រព្យទាំងនោះ ជាធាតុដាច់ដោយឡែកពីគ្នា។ ឧទាហរណ៍ ដូចជា ថ្នាក់ខុសគ្នានៃទ្រព្យ រោងចក្រនិងបរិក្ខា អាចត្រូវបានធ្វើឡើងតាមថ្លៃដើមឬតាមបរិមាណ ស្របតាមស្តង់ដា គណនេយ្យ អន្តរជាតិ ១៦។

## ការបែងចែកដាច់រវាងរយៈពេលខ្លី និងរយៈពេលវែង

៦០ អង្គភាពត្រូវបង្ហាញទ្រព្យសកម្មរយៈពេលខ្លី និងរយៈពេលវែង ព្រមទាំងបំណុលរយៈពេលខ្លីនិងរយៈពេលវែង ដោយចាត់ថ្នាក់ដាច់ដោយឡែកពីគ្នានៅក្នុង របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ ស្របតាម កថាខណ្ឌ **៦៦-៧៦** លើកលែងតែនៅពេលដែលការបង្ហាញដោយផ្អែកលើមូលដ្ឋានសន្ទនីយភាព ផ្តល់នូវព័ត៌មានដែលគួរឱ្យទុកចិត្ត និងមានការពាក់ព័ន្ធ។

នៅពេលដែលអនុវត្តការលើកលែងនោះ អង្គភាពត្រូវបង្ហាញនូវរាល់ទ្រព្យសកម្ម និងបំណុលទាំងអស់តាមលំដាប់លំដោយនៃសន្ទនីយភាព។

៦១ ទោះបីជា អង្គភាពអនុម័តរើសយកវិធីសាស្ត្របង្ហាញមួយណាក៏ដោយក៏អង្គភាពត្រូវតែលាតត្រដាង អំពីបរិមាណទឹកប្រាក់ ដែលគេរំពឹងថានឹងទទួលបាន ឬនឹងត្រូវទូទាត់នៅក្នុងពេល ១២ ខែក្រោយមក សម្រាប់ធាតុនៃទ្រព្យសកម្មនិងបំណុលពាក់ព័ន្ធនិមួយៗដែលរួមបញ្ចូលគ្នានូវបរិមាណទឹកប្រាក់ដែលរំពឹងថានឹងទទួលបានមកវិញ ឬបំណុលដែលរំពឹងថាបានសង :

(ក)មិនលើសពី ១២ ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ និង

(ខ)លើសពី ១២ ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។

៦២ នៅពេលដែលអង្គភាពផ្គត់ផ្គង់ទំនិញ ឬសេវាក្នុងវដ្តប្រតិបត្តិការដែលអាចកំណត់បានជាក់លាក់ ការចាត់ថ្នាក់ដាច់ដោយឡែកនៃទ្រព្យសកម្ម និងបំណុលរយៈពេលខ្លីនិងរយៈពេលវែងនៅក្នុងរបាយការណ៍ ស្តីពីស្ថានភាពហិរញ្ញវត្ថុ ផ្តល់នូវព័ត៌មានមានប្រយោជន៍ ដោយធ្វើការញែកចេញនូវទ្រព្យសកម្មសរុបដែលបន្តធ្វើចរាចរជាទុនបង្វិលពី ទ្រព្យសកម្មដែលបានប្រើនៅក្នុងប្រតិបត្តិការ រយៈពេលវែងរបស់អង្គភាព ។ វាក៏បង្ហាញឱ្យឃើញនូវទ្រព្យសកម្មដែលរំពឹងថានឹងសម្រេចបានក្នុងវដ្តនៃ ប្រតិបត្តិការបច្ចុប្បន្នហើយបំណុលដែលដល់កាលកំណត់សងក្នុងកំឡុងការិយបរិច្ឆេទដូចគ្នា។

៦៣ សម្រាប់អង្គភាពខ្លះ ដូចជា ស្ថាប័នហិរញ្ញវត្ថុ ការបង្ហាញនូវទ្រព្យសកម្ម និងបំណុលតាមលំដាប់លំដោយឡើងឬថយចុះនៃសន្ទនីយភាពផ្តល់នូវព័ត៌មានដែលគួរឱ្យទុកចិត្ត និងកាន់តែមានភាពទាក់ទិនជាង ការបង្ហាញ

នូវទ្រព្យនិងបំណុលទាំងនោះតាមរយៈពេលខ្លីវែង ពីព្រោះថាអង្គភាពមិនផ្តត់ផ្គង់ទំនិញឬសេវាក្នុងវដ្តប្រតិបត្តិការដែលអាចកំណត់បានជាក់លាក់។

៦៤ ក្នុងការអនុវត្តកថាខណ្ឌ ៦០ អង្គភាពត្រូវបានអនុញ្ញាតឱ្យ បង្ហាញនូវទ្រព្យសកម្ម និងបំណុលរបស់ខ្លួនខ្លះដោយធ្វើការចាត់ថ្នាក់ជារយៈពេលខ្លី-វែង និងទ្រព្យសកម្មផ្សេងទៀតតាមលំដាប់នៃសន្ទនីយភាព នៅពេលដែលការធ្វើដូចនេះផ្តល់នូវព័ត៌មានគួរឱ្យទុកចិត្ត និងការតែមានភាពទាក់ទិន។ តម្រូវការក្នុងការយកមូលដ្ឋានចម្រុះដើម្បីធ្វើការបង្ហាញអាចកើតមាន នៅពេលដែលអង្គភាពមានប្រតិបត្តិការច្រើនមិនទៀងទាត់។

៦៥ ព័ត៌មានអំពីកាលបរិច្ឆេទ ដែលបានរំពឹងទុកក្នុងការសម្រេចបាននូវទ្រព្យសកម្ម ឬបំណុល មានអត្ថប្រយោជន៍ក្នុងការវាយតម្លៃសន្ទនីយភាព និងស្ថានភាពរបស់អង្គភាព។ ស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិ ៧ ស្តីពី*ឧបករណ៍ហិរញ្ញវត្ថុ : ការលាតត្រដាងព័ត៌មាន*តម្រូវ ឱ្យធ្វើការលាតត្រដាងព័ត៌មាន អំពីការដល់កាលកំណត់នៃ ទ្រព្យសកម្ម ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ ទ្រព្យសកម្មហិរញ្ញវត្ថុរួមបញ្ចូលនូវចំណូល និងចំណូលត្រូវទទួលផ្សេងទៀតហើយបំណុលហិរញ្ញវត្ថុរួមមានចំណាយ និងទឹកប្រាក់ត្រូវសងផ្សេងទៀត។ ព័ត៌មានអំពីកាលបរិច្ឆេទដែលបានរំពឹងទុកនៃការទទួលបានមកវិញនូវទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដូចជាសន្និធិ និងកាលបរិច្ឆេទដែលបានរំពឹងទុកនៃការទូទាត់បំណុលដូចជាសំវិធានធន ក៏មានប្រយោជន៍ផងដែរទោះបីជាទ្រព្យសកម្មឬបំណុលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម ឬបំណុលរយៈពេលខ្លី ឬវែងក៏ដោយ។ ឧទាហរណ៍ ដូចជាអង្គភាពមួយ ដែលលាតត្រដាងព័ត៌មាន អំពីបរិមាណនៃសន្និធិ ដែលបាន

រំពឹងថាអាចទទួលបានមកវិញលើសពីរយៈពេល ១២ ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។

**<u>ទ្រព្យសកម្មរយៈពេលខ្លី</u>**

៦៦ អង្គភាពមួយ ត្រូវចាត់ថ្នាក់ទ្រព្យសកម្មមួយថាជា ទ្រព្យសកម្មរយៈពេលខ្លី នៅពេលដែល :

(ក) អង្គភាពរំពឹងថានឹងទទួលបានទ្រព្យសកម្ម ឬមានបំណងលក់ ឬប្រើប្រាស់ទ្រព្យនោះ ក្នុងវដ្តប្រតិបត្តិការជាធម្មតារបស់ខ្លួន។

(ខ) អង្គភាពកាន់កាប់ទ្រព្យសកម្ម ជាដំបូងក្នុងបំណង សម្រាប់លក់ទៅវិញ

(គ) អង្គភាពរំពឹងថាទទួលបានទ្រព្យសកម្មក្នុងកំឡុងពេល ១២ ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ឬ

(ឃ) ទ្រព្យសកម្មជាសាច់ប្រាក់ឬសាច់ប្រាក់ប្រហែល (ដូចបានកំណត់ក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៧) វាលែងតែទ្រព្យសកម្មត្រូវបានដាក់លក្ខខណ្ឌថាមិនអាចផ្តោះប្តូរបាន ឬទ្រព្យនោះត្រូវបានប្រើប្រាស់សម្រាប់ទូទាត់បំណុលក្នុងរយៈពេលយ៉ាងហោចណាស់ ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

អង្គភាពត្រូវចាត់ថ្នាក់នូវ រាល់ទ្រព្យសកម្មដ៏ទៃទៀតជា ទ្រព្យសកម្មរយៈពេលវែង។

៦៧ ស្តង់ដានេះប្រើពាក្យ “រយៈពេលវែង” ដោយរួមបញ្ចូលទាំងទ្រព្យសកម្មរូបិយ ទ្រព្យសកម្មអរូបិយ និងទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខណៈរយៈ

ពេលវែង។ ស្តង់ដានេះ មិនហាមឃាត់ការប្រើប្រាស់ការពិពណ៌នាតាមជម្រើស ដរាបណាអត្ថន័យរបស់វាមានភាពច្បាស់លាស់។

៦៨ វដ្តនៃប្រតិបត្តិការរបស់អង្គភាពមួយគឺជាពេលវេលារវាងការទទួលបាននូវទ្រព្យសកម្មសម្រាប់យកមកដំណើរការ និងការទទួលបានជាសាច់ប្រាក់ឬសាច់ប្រាក់ប្រហាក់ប្រហែលពី ទ្រព្យសកម្មនោះ។ នៅពេលដែលវដ្តប្រតិបត្តិការធម្មតារបស់អង្គភាពមិនត្រូវបានកំណត់ច្បាស់លាស់ទេវដ្តនោះត្រូវបានសន្មត់ថាមានរយៈពេល ១២ ខែ។ ទ្រព្យសកម្មរយៈពេលខ្លីរួមមានទ្រព្យសកម្មដែលបានលក់ បានប្រើប្រាស់ឬទទួលបាន(ដូចជាសន្និធិ និងចំណូលដែលនឹងទទួលបានពីការលក់) ជាផ្នែកមួយនៃ វដ្តប្រតិបត្តិការធម្មតា ទោះបីជានៅពេលដែលទ្រព្យនោះមិនត្រូវបានរំពឹងថាទទួលបានក្នុងកំឡុងពេល ១២ខែ បន្ទាប់ពីការិយ-បរិច្ឆេទរាយការណ៍។ ទ្រព្យសកម្មរយៈពេលខ្លី ក៏រាប់បញ្ចូលផងដែរនូវទ្រព្យសកម្មដែលដំបូងឡើយត្រូវបានរក្សាទុកសម្រាប់លក់(ឧទាហរណ៍រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននិយមន័យនៃការរក្សាទុកសម្រាប់លក់ ក្នុងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៩) និង ផ្នែកជាក់ស្តែងនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុ)។

## <u>បំណុលរយៈពេលខ្លី</u>

៦៩ អង្គភាពមួយត្រូវចាត់ថ្នាក់បំណុលមួយថាជា បំណុលរយៈពេលខ្លីនៅពេលដែល :

(ក)អង្គភាពរំពឹងថា នឹងទូទាត់បំណុលនៅក្នុង វដ្តប្រតបិត្តិការធម្មតារបស់ខ្លួន។

(ខ)អង្គភាពរក្សាបំណុលរបស់ខ្លួនជាបឋមសម្រាប់ការរកស៊ុ
(គ)បំណុល បានដល់កាលកំណត់សងក្នុងកំឡុងពេល១២ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ឬ
(ឃ)អង្គភាពពុំមានសិទ្ធិគ្មានលក្ខខណ្ឌក្នុងការពន្យាការទូទាត់បំណុល ក្នុងរយៈពេលយ៉ាងហោចណាស់ ១២ ខែ បន្ទាប់ពីការិយបរិច្ឆេទ រាយការណ៍ (សូមមើលកថាខណ្ឌ ៧៣)។ តាមជម្រើសរបស់ បដិភាគី លក្ខខណ្ឌនៃបំណុលដែលអាចនាំឱ្យមានការទូទាត់តាម រយៈការបោះផ្សាយឧបករណ៍មូលធនផ្ទាល់ មិននាំឱ្យប៉ះពាល់ដល់ ការចាត់ថ្នាក់បំណុលនោះទេ។

អង្គភាព ត្រូវចាត់ថ្នាក់នូវរាល់បំណុលដទៃទៀត ជាបំណុលរយៈពេលវែង។

៧០ បំណុលរយៈពេលខ្លីខ្លះ ដូចជា ចំណាយដែលត្រូវទូទាត់ និងចំណាយបូកយោងសម្រាប់បុគ្គលិកនិងចំណាយប្រតិបត្តិការដទៃទៀត គឺជាផ្នែកមួយនៃទុនបង្វិល ដែលត្រូវបានប្រើប្រាស់ក្នុងវដ្តប្រតិបត្តិការអាជីវកម្មជាធម្មតារបស់អង្គភាព។ អង្គភាពចាត់ថ្នាក់នូវធាតុនានា នៃប្រតិបត្តិការនេះជាបំណុលរយៈពេលខ្លី ទោះបីជាធាតុទាំងនោះត្រូវបានដល់កាលកំណត់សងលើសពី ១២ ខែបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ក៏ដោយ។ វដ្តនៃប្រតិបត្តិការជាធម្មតាដូចគ្នា អនុវត្តចំពោះការចាត់ថ្នាក់ទ្រព្យសកម្ម និងបំណុលរបស់ អង្គភាព។ នៅពេលដែលវដ្តប្រតិបត្តិការជាធម្មតារបស់អង្គភាព មិនអាចត្រូវបានកំណត់ច្បាស់លាស់ វាត្រូវបានសន្មត់ថាមានរយៈពេល ១២ ខែ។

៧១ បំណុលរយៈពេលខ្លីដទៃទៀត មិនត្រូវបានទូទាត់សងជាផ្នែកមួយនៃវដ្តប្រតិបត្តិការជាធម្មតានោះទេប៉ុន្តែវាត្រូវដល់កាលកំណត់សងក្នុងរយៈពេល

១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ឬត្រូវបានថែរក្សាជាពីដំបូងថាទុកសម្រាប់លក់ ។ ឧទាហរណ៍នានា គឺជាបំណុលហិរញ្ញវត្ថុមួយចំនួនដែលបំពេញបានតាមនិយមន័យស្ដីពី ការថែរក្សាសម្រាប់លក់ក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៩ ដូចជា ឥណទានវិបារូប៍ និងផ្នែកជាក់ស្ដែងនៃបំណុលហិរញ្ញវត្ថុរយៈពេលវែង ភាគលាភដែលត្រូវបែងចែក ពន្ធលើប្រាក់ចំណូល និងការទូទាត់មិនមែនពាណិជ្ជកម្មដទៃទៀត។ បំណុលហិរញ្ញវត្ថុដែលផ្ដល់ហិរញ្ញប្បទានដោយឈរលើមូលដ្ឋានរយៈពេលវែង (មានន័យថា មិនមែនជាផ្នែកមួយនៃទុនបង្វិលដែលបានប្រើប្រាស់ក្នុងវដ្តប្រតិបត្តិការជាធម្មតារបស់អង្គភាព) ហើយដែលមិនដល់កាលកំណត់សង ក្នុងកំឡុងពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយ-ការណ៍ គឺមិនមែនជាបំណុលរយៈពេលវែងដែលជាកម្មវត្ថុនៃកថាខណ្ឌ ៧៤ និង ៧៥ នោះទេ ។

៧២ អង្គភាពមួយ ចាត់ថ្នាក់បំណុលហិរញ្ញវត្ថុរបស់ខ្លួនថាជាបំណុលរយៈពេលវែង នៅពេលដែលបំណុលទាំងនោះដល់កាលកំណត់សងក្នុងកំឡុងពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ទោះបីជា :

(ក) លក្ខខណ្ឌដើម បានកំណត់កាលបរិច្ឆេទលើសពី ១២ ខែ និង

(ខ) មានកិច្ចព្រមព្រៀង ដើម្បីហិរញ្ញប្បទានឡើងវិញ ឬកំណត់កាលបរិច្ឆេទបង់សងឡើងវិញ ដោយឈរលើ មូលដ្ឋានរយៈពេលវែង ត្រូវបានបំពេញចប់បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍និងមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ។

៧៣ ប្រសិនបើ អង្គភាពមានសិទ្ធិអំណាច ហើយរំពឹងថានឹងធ្វើហិរញ្ញប្បទានឡើងវិញ ឬលើកកាតព្វកិច្ចសងរយៈពេលយ៉ាងហោចណាស់១២ខែបន្ទាប់

ពីការិយបរិច្ឆេទរាយការណ៍ ក្រោមលក្ខខណ្ឌបន្ទុរបន្ថយកម្ចី ដែលមានស្រាប់ អង្គភាពត្រូវចាត់ថ្នាក់កាតព្វកិច្ចសងបំណុលជាកាតព្វកិច្ចរយៈពេលវែង ទោះបីវាត្រូវដល់កាលកំណត់សង ក្នុងការិយបរិច្ឆេទខ្លីជាងនេះក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលការធ្វើហិរញ្ញប្បទានឡើងវិញ ឬការលើកកាតព្វកិច្ច មិនមែនជាសិទ្ធិអំណាចរបស់អង្គភាពទេ (ឧទាហរណ៍ដូចជាពុំមានការសន្យាធ្វើហិរញ្ញប្បទានឡើងវិញទេ) អង្គភាពមិនត្រូវពិចារណាលើ សក្តានុពលនៃការធ្វើ ហិរញ្ញប្បទានឡើវិញលើបំណុលជាកាតព្វកិច្ច និងចាតថ្នាក់បំណុលជាកាតព្វកិច្ចនោះថាជា បំណុលរយៈពេលខ្លីនោះទេ ។

៧៤ នៅពេលដែលអង្គភាពបំពាន នៃកិច្ចសន្យាកម្ចីរយៈពេលវែងនាចុង ឬមុនការិយបរិច្ឆេទរាយការណ៍ ដោយធ្វើឱ្យបំណុលអាចសងបានតាមការទាមទារ អង្គភាពចាត់ថ្នាក់បំណុលជាបំណុលរយៈពេលខ្លី ទោះបីជាម្ចាស់បំណុលយល់ព្រមបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ និងមុនការអនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ ហើយមិនមែនស្នើឱ្យទូទាត់បំណុលដោយសារ តែការបំពានកិច្ចសន្យានោះទេ។ នាចុងការិយបរិច្ឆេទរាយ-ការណ៍ អង្គភាពចាត់ថ្នាក់បំណុលថាជា បំណុលរយៈពេលខ្លី ព្រោះថា អង្គភាពមិនមានសិទ្ធិគ្មានលក្ខខណ្ឌ ក្នុងការពន្យាការទូទាត់ បំណុលយ៉ាងហោចណាស់រយៈពេល ១២ខែ បន្ទាប់ពី កាលបរិច្ឆេទ ។

៧៥ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គភាពចាត់ថ្នាក់បំណុល ថាជាបំណុលរយៈពេលវែង ប្រសិនបើម្ចាស់បំណុល បានយល់ព្រមនាចុងកាយរិយបរិច្ឆេទរាយការណ៍ ដើម្បីផ្តល់ការិយបរិច្ឆេទមួយសមរម្យ ដែលបញ្ចប់យ៉ាងហោចណាស់ ១២ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ដែលក្នុង កំ

ឡុងពេលនោះ អង្គភាពអាចកែតម្រូវក្នុងការបំពាន ហើយក្នុងកំឡុង ពេលនោះ ម្ចាស់បំណុលមិនអាចស្នើឱ្យទូទាត់ឡើងវិញភ្លាមៗនោះទេ ។

៧៦ ចំពោះបំណុល ដែលបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី ប្រសិនបើព្រឹត្តិការណ៍ដូចខាងក្រោមនេះបានកើតឡើង ក្នុងចន្លោះចុងការិយបរិច្ឆេទរាយការណ៍ និងកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតបោះផ្សាយ ព្រឹត្តិការណ៍ទាំងនោះ ត្រូវបានលាតត្រដាងថាជាព្រឹត្តិការណ៍ដែលមិនបានកែតម្រូវ ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិ ១០ ស្តីពី *ព្រឹត្តិការណ៍ ក្រោយការិយបរិច្ឆេទរាយការណ៍*:

(ក) ការធ្វើហិរញ្ញប្បទានឡើងវិញផ្អែកលើមូលដ្ឋានរយៈពេលវែង
(ខ) ការកែតម្រូវលើការបំពានកិច្ចសន្យាខ្ចីប្រាក់រយៈពេលវែង និង
(គ) ការផ្តល់នូវការិយបរិច្ឆេទសមរម្យ ដោយម្ចាស់បំណុល ដើម្បីកែតម្រូវការបំពានកិច្ចសន្យាខ្ចីប្រាក់រយៈពេលវែង ដែលបានបញ្ចប់យ៉ាងហោចណាស់ ១២ ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ។

## ព័ត៌មានដែលត្រូវបង្ហាញទាំងក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ និងទាំងក្នុងកំណត់សម្គាល់

៧៧ ទាំងនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ និងទាំងកំណត់សម្គាល់ អង្គភាពត្រូវលាតត្រដាងព័ត៌មាន អំពីការចាត់ថ្នាក់រងបន្ថែមទៀតនៃធាតុពាក់ព័ន្ធនានា ដែលបានបង្ហាញ និងបានចាត់ថ្នាក់ត្រឹមត្រូវចំពោះប្រតិ-បត្តិការរបស់អង្គភាព។

៧៨ ព័ត៌មានលម្អិត ដែលផ្តល់នៅក្នុងចំណាត់ថ្នាក់រង គឺអាស្រ័យដោយការតម្រូវរបស់ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ និងអាស្រ័យ

ដោយទំហំ ប្រភេទ និងតួនាទីនិងបរិមាណដែលពាក់ព័ន្ធ ។ អង្គភាព ក៏ប្រើកត្តានានាដែលបានកំណត់នៅក្នុងកថាខណ្ឌ ៥៨ ដែរ ដើម្បីធ្វើការសម្រេចចិត្តរើសយកការធ្វើចំណាត់ថ្នាក់រង។ការលាតត្រដាង នៃការប្រែប្រួល តាមធាតុនិមួយៗ ឧទាហរណ៍ដូចជា :

(ក) ធាតុនានានៃទ្រព្យ រោងចក្រ និងបរិក្ខា ត្រូវបានបំបែកជាថ្នាក់ស្រប តាមស្តង់ដាគណនេយ្យអន្តរជាតិ ១៦

(ខ) ចំណូលដែលនឹងទទួលបាន ដែលត្រូវបានបំបែកជាបរិមាណចំណូលពីអតិថិជន ចំណូលពីភាគីពាក់ព័ន្ធ ការទូទាត់មុន និងបរិមាណទឹកប្រាក់ដទៃទៀត ។

(គ) ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិ ២ ស្តីពី*សន្និធិ* សន្និធិនានាដែលបានបំបែកជាថ្នាក់ ដូចជា ទំនិញ សម្ភារៈផ្គត់ផ្គង់ផលិតកម្ម សម្ភារៈផ្សេងៗ ផលិតផលមិនទាន់សម្រេច និងផលិតផលសម្រេច នានា។

(ឃ) សំវិធានធន ដែលត្រូវបានបំបែកជាសំវិធានធនសម្រាប់អត្ថប្រយោជន៍បុគ្គលិក និងធាតុដទៃទៀត និង

(ង) ដើមទុន ជាមូលធនផ្ទាល់ និងទុនបម្រុង ដែលបានបំបែកជាថ្នាក់ ផ្សេងៗ ដូចជាដើមទុនដែលបានបង់ បុព្វលាភភាគហ៊ុន និងទុន បម្រុង។

៧៩ ទាំងក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ និងទាំងក្នុងរបាយការណ៍ស្តីពីការប្រែប្រួល នៃមូលធនផ្ទាល់ និងទាំងក្នុងកំណត់សម្គាល់ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម :

(ក) សម្រាប់ថ្នាក់និមួយៗនៃដើមទុនជាភាគហ៊ុន :

១- ចំនួននៃភាគហ៊ុនដែលបានអនុញ្ញាត

២-ចំនួននៃភាគហ៊ុនដែលបានបោះផ្សាយ និងដែលបានបង់ផ្តាច់ និងភាគហ៊ុនដែលបានបោះផ្សាយតែមិនទាន់បង់ផ្តាច់ទាំងស្រុង
៣-តម្លៃចារិកក្នុងមួយសន្លឹកហ៊ុនឬដែលសន្លឹកហ៊ុនពុំមានតម្លៃចារិក
៤-ការផ្ទៀងផ្ទាត់នៃចំនួនសន្លឹកហ៊ុន ដែលមាននាដើមនិងចុងការិយបរិច្ឆេទ
៥-សិទ្ធិប៉ុរិមា និងលក្ខខណ្ឌកំណត់ដែលភ្ជាប់ជាមួយថ្នាក់ នោះ រួមបញ្ចូលទាំងលក្ខខណ្ឌនៃការបែងចែកភាគលាភ និងការបង់សងឡើងវិញនៃដើមទុន។
៦-ភាគហ៊ុននៅក្នុងមូលធនផ្ទាល់ ដែលកាន់កាប់ដោយអង្គភាព ឬដោយក្រុមហ៊ុនញាតិសម្ព័ន្ធឬបុត្រសម្ព័ន្ធ និង
៧-ភាគហ៊ុនដែលបម្រុងទុកបោះផ្សាយ ក្រោមជម្រើសនិងកិច្ចសន្យាលក់ភាគហ៊ុនរួមបញ្ចូលទាំងលក្ខខណ្ឌនិងបរិមាណទឹកប្រាក់ព្រមទាំង

(ខ) ការពិពណ៌នានៃប្រភេទនិងគោលបំណងនៃទុនបម្រុងនិមួយៗក្នុងមូលធនផ្ទាល់។

៨០ អង្គភាពដែលគ្មានដើមទុនជាភាគហ៊ុន ដូចជា ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ **trust** ត្រូវលាតត្រដាងព័ត៌មានប្រហាក់ប្រហែលនឹងព័ត៌មានដែលតម្រូវដោយកថាខណ្ឌ ៧៩(ក) ដោយបង្ហាញអំពីការប្រែប្រួលក្នុងកំឡុងការិយបរិច្ឆេទលើប្រភេទនិមួយៗនៃភាគកម្មមូលធនផ្ទាល់ និងសិទ្ធិ សិទ្ធិប៉ុរិមា ព្រមទាំងលក្ខខណ្ឌកំណត់ ដែលភ្ជាប់ជាមួយប្រភេទនិមួយៗ នៃភាគកម្មមូលធនផ្ទាល់។

៨០ក ប្រសិនបើអង្គភាពបានធ្វើចំណាត់ថ្នាក់ឡើងវិញនូវ :

(ក) ឧបករណ៍ហិរញ្ញវត្ថុដែលអាចដាក់លក់បាន ដែលបានចាត់ថ្នាក់ថាជាឧបករណ៍មូលធនផ្ទាល់ ឬ

(ខ) ឧបករណ៍មួយដែលដាក់កាតព្វកិច្ចលើអង្គភាព ក្នុងការផ្តល់ដល់អង្គភាពដទៃទៀតនូវចំណែក ដែលមានរួចស្រេច នៃទ្រព្យសកម្មសុទ្ធរបស់អង្គភាព លើតែសន្ទនីយភាព ហើយឧបករណ៍នោះត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធនផ្ទាល់

រវាងបំណុលហិរញ្ញវត្ថុ និងមូលធនផ្ទាល់ នោះអង្គភាពត្រូវលាតត្រដាងនូវបរិមាណទឹកប្រាក់ ដែលបានចាត់ថ្នាក់ឡើងវិញក្នុង និងក្រៅប្រភេទនីមួយៗ (បំណុលហិរញ្ញវត្ថុ ឬមូលធនផ្ទាល់) ព្រមទាំងលាតត្រដាង អំពីពេលវេលានិងហេតុផលនៃការចាត់ថ្នាក់ឡើងវិញ។

## របាយការណ៍ស្តីពីចំណូលបន្ទាប់បន្សំ

៨១ អង្គភាពត្រូវបង្ហាញនូវរាល់ធាតុនានា នៃចំណូលនិងចំណាយ ដែលបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទមួយ :

(ក) នៅក្នុងរបាយការណ៍ចំណូលបន្ទាប់បន្សំតែមួយ ឬ

(ខ) ក្នុងរបាយការណ៍ ២ : របាយការណ៍ដែលបង្ហាញឱ្យឃើញនូវសមាសធាតុ នៃចំណេញ ឬខាត (របាយការណ៍លទ្ធផលដាច់ដោយឡែក) និងរបាយការណ៍ទី២ ដែលផ្តើមដោយចំណេញ ឬខាត ព្រមទាំងបង្ហាញនូវសមាសធាតុ នៃចំណូលបន្ទាប់បន្សំដទៃទៀត (របាយការណ៍ ចំណូលបន្ទាប់បន្សំ)។

## ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ស្ដីពីចំណូលបន្ទាប់បន្សំ

៨២ យ៉ាងហោចណាស់ របាយការណ៍ស្ដីពីចំណូលបន្ទាប់បន្សំ ត្រូវរួមបញ្ចូលនូវធាតុពាក់ព័ន្ធនានា ដោយបង្ហាញនូវបរិមាណ ទឹកប្រាក់សម្រាប់ការិយ-បរិច្ឆេទដូចខាងក្រោម :

(ក) ចំណូល

(កក) ចំណេញ និងការខាតបង់ដែលកើតពីការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែងតាមថ្លៃដើម រំលោះ

(ខ) ថ្លៃដើមហិរញ្ញប្បទាន

(គ) ចំណែកនៃប្រាក់ចំណេញឬខាតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ

(គក) ទ្រព្យសកម្ម ត្រូវបានវាស់វែងតាមថ្លៃទីផ្សារ នោះចំណេញ ឬការខាតបង់ដែលកើតចេញពីភាពខុសគ្នារវាងតម្លៃក្នុងបញ្ជីពីពេលមុន និងតម្លៃទីផ្សាររបស់វានាកាលបរិច្ឆេទធ្វើចំណាត់ថ្នាក់ឡើងវិញ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ឡើងវិញ។

(ឃ) ចំណាយបង់ពន្ធ

(ង) បរិមាណរួមមួយដែលមានចំនួនសរុបនៃ :

១- ចំណេញឬខាតក្រោយការបង់ពន្ធនៃប្រតិបត្តិការមិនបន្ត និង

២- ចំណេញឬខាតក្រោយបង់ពន្ធ ដែលត្រូវបានទទួលស្គាល់លើធ្វើការវាស់វែង ដោយយកតម្លៃទីផ្សារ ដក ថ្លៃដើមលក់ និងដែលបានទទួលស្គាល់លើការលក់បញ្ចេញចោលនូវទ្រព្យសកម្ម ឬការលក់បញ្ចេញចោលនូវបណ្ដុំ នៃទ្រព្យសកម្ម ដែលបង្កើតបានជាប្រតិបត្តិការមិនបន្ត។

(ច) ចំណេញឬខាត

(ឆ)សមាសធាតុនីមួយៗនៃ ចំណូលបន្ទាប់បន្សំដទៃទៀត ដែលបាន ចាត់ថ្នាក់តាមប្រភេទ (ដកចេញនូវបរិមាណនៅក្នុងចំណុច ជ)

(ជ)ចំណែកនៃ ចំណូលបន្ទាប់បន្សំផ្សេងៗទៀតរបស់ ក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ដែលបានគណនាដោយប្រើវិធីសាស្ត្រមូលធនផ្ទាល់ និង

(ឈ)ចំនួនសរុបនៃចំណូលបន្ទាប់បន្សំ។

៨៣ អង្គភាពត្រូវលាតត្រដាងអំពីធាតុនានាដូចខាងក្រោមនៅក្នុងចំណូលបន្ទាប់បន្សំ ថាជាវិភាជន៍សម្រាប់ការិយបរិច្ឆេទ :

(ក)ចំណេញឬខាតសម្រាប់ការិយបរិច្ឆេទ ដែលអាចផ្តល់ជូន

១-ជាភាគកម្មដែលមិនមានសិទ្ធិត្រួតពិនិត្យ និង

២-ចំពោះម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុនមេ។

(ខ)ចំណូលបន្ទាប់បន្សំសរុបសម្រាប់ការិយបរិច្ឆេទដែលអាចផ្តល់ជូន

១-ជាភាគកម្មដែលមិនមានសិទ្ធិត្រួតពិនិត្យ និង

២-ចំពោះម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុនមេ។

៨៤ អង្គភាព អាចបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល ដាច់ដោយឡែកមួយ (សូមមើលកថាខណ្ឌ ៨១) នូវរាល់ធាតុពាក់ព័ន្ធនានាក្នុងកថាខណ្ឌ ៨២ (ក)-(ច) និងការលាតត្រដាងនៅក្នុងកថាខណ្ឌ ៨៣(ក)។

៨៥ អង្គភាពត្រូវបង្ហាញនូវធាតុពាក់ព័ន្ធបន្ថែមទៀត ចំណងជើងនិងចំនួនសរុបរងក្នុងរបាយការណ៍ ស្តីពីចំណូលបន្ទាប់បន្សំ និងនៅក្នុងរបាយការណ៍លទ្ធផល ដាច់ដោយឡែក (ប្រសិនត្រូវបានបង្ហាញ) នៅពេលដែលការបង្ហាញនេះបានការពាក់ព័ន្ធដល់ការយល់ដឹងអំពី ប្រតិបត្តិការហិរញ្ញវត្ថុរបស់ អង្គភាព។

៨៦ ដោយសារតែឥទ្ធិពលនៃសកម្មភាពផ្សេងៗរបស់អង្គភាពប្រតិបត្តិការ និង ព្រឹត្តិការណ៍ដទៃទៀត ជាញឹកញាប់ មានភាពខុសគ្នារវាងសក្តានុពលនៃ ចំណេញឬខាតនិងការព្យាករណ៍ចំណេញដោយលាតត្រដាងនូវសមាសធាតុ នៃប្រតិបត្តិការហិរញ្ញវត្ថុ ជួយដល់អ្នកប្រើប្រាស់យល់ដឹងអំពីប្រតិបត្តិការ ដែលសម្រេចបាន និងជួយក្នុងការព្យាករណ៍ប្រតិបត្តិការហិរញ្ញវត្ថុនាពេល អនាគត។ អង្គភាពមួយបញ្ចូលនូវធាតុពាក់ព័ន្ធបន្ថែមក្នុងរបាយការណ៍ស្តីពី ចំណូលបន្ទាប់បន្សំនិងក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែក(ប្រសិន បើត្រូវបង្ហាញ) ព្រមទាំងកែប្រែនូវការពិពណ៌នា ដែលបានប្រើប្រាស់ និង កែប្រែនូវលំដាប់លំដោយនៃធាតុនានា នៅពេលមានការចាំបាច់ក្នុងការ ពន្យល់នូវធាតុនានានៃប្រតិបត្តិការហិរញ្ញវត្ថុ។ អង្គភាពត្រូវពិចារណាលើ កត្តានានារួមទាំងភាពជាសារវន្តព្រមទាំងប្រភេទនិងតួនាទីរបស់ធាតុនានា នៃចំណូលនិងចំណាយ។ឧទាហរណ៍ ដូចជា ស្ថាប័នហិរញ្ញវត្ថុមួយអាចកែ ប្រែការពិពណ៌នា ដើម្បីផ្តល់ព័ត៌មានដែលទាក់ទងនឹងប្រតិបត្តិការរបស់ ស្ថាប័នហិរញ្ញវត្ថុនោះ។ អង្គភាព មិនត្រូវកាត់កងរវាងធាតុនៃចំណូល និង ចំណាយវាលែងតែបំពេញបានតាមលក្ខណៈវិនិច្ឆ័យក្នុងកថាខណ្ឌ ៣២។

៨៧ អង្គភាព មិនត្រូវបង្ហាញនៅក្នុងរបាយការណ៍ចំណូលបន្ទាប់បន្សំ ឬក្នុង របាយការណ៍លទ្ធផល ដាច់ដោយឡែក (ប្រសិនត្រូវបង្ហាញ) ឬនៅក្នុង កំណត់សម្គាល់ នូវធាតុនៃចំណូលឬចំណាយណា ថាជាធាតុពិសេសនោះ ទេ។

## ចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទ

៨៨ អង្គភាព ត្រូវទទួលស្គាល់នូវរាល់ធាតុនានានៃចំណូល និងចំណាយក្នុងការិយបរិច្ឆេទមួយក្នុងចំណេញ ឬខាត វាលែងតែមានស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិណាមួយតម្រូវ ឬអនុញ្ញាតផ្សេងពីនេះ។

៨៩ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិខ្លះ បញ្ជាក់ដាច់ដោយឡែកនូវ កាលទេសៈនានា នៅពេលដែលអង្គភាពទទួលស្គាល់នូវធាតុពិសេសនៅក្រៅចំណេញ ឬខាតនាការិយបរិច្ឆេទបច្ចុប្បន្ន ។ ស្តង់ដាគណ- នេយ្យអន្តរជាតិ ៨ បានកំណត់ជា ពិសេសនូវកាលទេសៈពីរបែបនេះ : ការកែតម្រូវកំហុសឆ្គង និងឥទ្ធិពលនៃការប្រែប្រួល គោលនយោបាយ គណនេយ្យ។ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិដទៃទៀត តម្រូវ ឬអនុញ្ញាតឱ្យមាននូវសមាសធាតុ នៃចំណូលបន្ទាប់បន្សំផ្សេងៗទៀតដែលបំពេញបានតាមនិយមន័យនៃចំណូល ឬចំណាយដែលត្រូវដកចេញពីចំណេញ ឬខាត នៅក្នុង*ក្របខណ្ឌស្តង់ដា** (សូមមើលកថាខណ្ឌ ៧ )។

## ចំណូលបន្ទាប់បន្សំដទៃទៀតសម្រាប់ការិយបរិច្ឆេទ

៩០ អង្គភាព ត្រូវលាតត្រដាងព័ត៌មានអំពីបរិមាណទឹកប្រាក់នៃពន្ធលើប្រាក់ចំណូល ទាក់ទិននឹងសមាសធាតុនីមួយៗ នៃចំណូលបន្ទាប់បន្សំផ្សេងៗទៀត ដោយរាប់បញ្ចូលទាំងការចាត់ថ្នាក់ឡើងវិញនូវការកែតម្រូវ ទាំងនៅក្នុងរបាយការណ៍ស្តីពីចំណូលបន្ទាប់បន្សំ និងទាំងក្នុងកំណត់សម្គាល់។

៩១ អង្គភាពអាចបង្ហាញនូវសមាសធាតុនៃចំណូលបន្ទាប់បន្សំ :

(ក) ទាំងចំនួនសរុបនៃអានុភាពពន្ធដែលទាក់ទិន និងទាំង

(ខ)ចំណូលមុនកាត់ពន្ធ ទាក់ទិនជាមួយចំនួនទឹកប្រាក់ ដែលបង្ហាញ ចំនួនសរុបរួមនៃពន្ធលើប្រាក់ចំណូល ពាក់ព័ន្ធទៅនឹងសមាសធាតុ ទាំងនោះ។

៩២ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីការចាត់ថ្នាក់ឡើងវិញនៃការកែតម្រូវ ពាក់ព័ន្ធនឹងចំណូលបន្ទាប់បន្សំដទៃទៀត។

៩៣ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិដទៃទៀតបានបញ្ជាក់ ថាតើនៅពេលណា ដែលចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ពីមុននៅ ក្នុងចំណូលបន្ទាប់បន្សំត្រូវបានចាត់ថ្នាក់ឡើងវិញនៅក្នុងចំណេញឬខាត។ ការចាត់ថ្នាក់ឡើងវិញបែបនេះ គឺសំដៅដល់ការចាត់ថ្នាក់ឡើងវិញនូវការ កែតម្រូវ នៅក្នុងស្តង់ដានេះ។ ការចាត់ថ្នាក់ឡើងវិញនូវការកែតម្រូវត្រូវ បានរួមបញ្ចូលជាមួយ សមាសធាតុពាក់ព័ន្ធ នៃចំណូលបន្ទាប់បន្សំក្នុង ការិយបរិច្ឆេទដែលការកែតម្រូវត្រូវបានចាត់ថ្នាក់ឡើងវិញនៅក្នុងចំណេញ ឬខាត។ចំនួនទឹកប្រាក់ទាំងនេះ អាចត្រូវបានទទួលស្គាល់នៅក្នុងចំណូល បន្ទាប់បន្សំដទៃទៀតថាជាចំណូលមិនអាចទទួលបានក្នុងការិយបរិច្ឆេទ បច្ចុប្បន្នឬក្នុងការិយបរិច្ឆេទមុនៗ។ ចំណូលដែលមិនបានទទួលទាំងនោះ ត្រូវតែកាត់ចេញពីចំណូលបន្ទាប់បន្សំដទៃទៀត នៅក្នុងកំឡុងការិយបរិច្ឆេទ ដែលចំណូល ដែលបានទទួលត្រូវបានចាត់ថ្នាក់ឡើងវិញទៅក្នុងចំណេញ ឬខាត ដើម្បីជៀសវាងការបញ្ចូលនូវចំណូលមិនបានទទួលទាំងនោះក្នុង ចំណូលបន្ទាប់បន្សំសរុប ២ ដង។

៩៤ អង្គភាពអាចបង្ហាញនូវការចាត់ថ្នាក់ឡើងវិញ នៃការកែតម្រូវក្នុង របាយ-ការណ៍ស្តីពីចំណូលបន្ទាប់បន្សំ ឬក្នុងកំណត់សម្គាល់។អង្គភាពដែលបង្ហាញ នូវការចាត់ថ្នាក់ឡើងវិញ នៃការកែតម្រូវក្នុង កំណត់សម្គាល់ បង្ហាញនូវ

សមាសធាតុនៃ ចំណូលបន្ទាប់បន្សំដទៃទៀត បន្ទាប់ពីមានការចាត់ថ្នាក់ឡើងវិញលើការកែតម្រូវពាក់ព័ន្ធកើតមានឡើង។

៩៥ ឧទាហរណ៍ ការចាត់ថ្នាក់ឡើងវិញលើការកែតម្រូវកើតពីការលក់បញ្ចេញចោលនូវ ប្រតិបត្តិការនៅក្រៅប្រទេស (សូមមើលស្តង់ដាគណនេយ្យអន្តរជាតិ២១) និងនៅពេលដែលការព្យាករណ៍លំហូរសាច់ប្រាក់ទប់ស្កាត់ហានិភ័យជះឥទ្ធិពលលើចំណេញ ឬខាត (សូមមើលកថាខណ្ឌ ១០០ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩)។

៩៦ ការចាត់ថ្នាក់ឡើងវិញ នៃការកែតម្រូវ មិនកើតចេញពី ការប្រែប្រួលនៃអតិរេក បានពីការវាយតម្លៃឡើងវិញ ដែលបានទទួលស្គាល់ស្របតាម ស្តង់ដាគណនេយ្យអន្តរជាតិ ១៦ ឬស្តង់ដាគណនេយ្យអន្តរជាតិ ៣៨ នោះទេ ឬបានពីចំណេញ ឬខាតពីការគណនាច្បាស់លាស់លើផែនការ អត្ថប្រយោជន៍ដែលបានគំណត់ទទួលស្គាល់ស្របតាមកថាខណ្ឌ ៩៣(ក) នៃស្តង់ដាគណនេយ្យអន្តរជាតិ ១៩។ សមាសធាតុទាំងនេះ ត្រូវបានទទួលស្គាល់នៅក្នុងចំណូលបន្ទាប់បន្សំដទៃទៀតនិងមិនត្រូវបានចាត់ថ្នាក់ ឡើងវិញលើចំណេញ ឬខាត នាការិយបរិច្ឆេទបន្តបន្ទាប់នោះទេ។ ការប្រែប្រួលលើអតិរេក នៃការវាយតម្លៃឡើងវិញ អាចត្រូវបានផ្ទេរចូលប្រាក់ចំណេញរក្សាទុកនាការិយបរិច្ឆេទបន្តបន្ទាប់ថាជា ទ្រព្យសកម្ម ដែលត្រូវប្រើប្រាស់ឬនៅពេលដែលទ្រព្យសកម្មនោះមិនត្រូវបានទទួលស្គាល់(សូមមើល ស្តង់ដាគណនេយ្យអន្តរជាតិ ១៦ និង ៣៨)។ ចំណេញ និងខាតដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ត្រូវបានរាយការណ៍នៅក្នុងប្រាក់ចំណេញរក្សាទុក ក្នុងការិយបរិច្ឆេទដែលចំណេញនិងខាតនោះត្រូវបានទទួលស្គាល់ជាចំណូលបន្ទាប់បន្សំដទៃទៀត។

**ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ស្ដីពីចំណូលបន្ទាប់បន្សំ ឬនៅក្នុងកំណត់សម្គាល់**

៩៧ នៅពេលដែលធាតុនានានៃចំណូល ឬចំណាយមានភាពជាសារវន្តអង្គភាពត្រូវលាតត្រដាងនូវព័ត៌មានអំពីប្រភេទ និងបរិមាណទឹកប្រាក់របស់វាដាច់ដោយឡែក។

៩៨ កាលទេសៈនានា ដែលនាំឱ្យមានការលាតត្រដាងដាច់ដោយឡែកនូវធាតុនានានៃចំណូលនិងចំណាយ រួមមាន :

(ក) ការថយចុះតម្លៃនៃសន្និធិពីតម្លៃពិត ដែលអាចស្ដារឡើងវិញបាន ឬការថយចុះតម្លៃនៃទ្រព្យ រោងចក្រ និងបរិក្ខាពីបរិមាណដែលអាចស្ដារមកវិញ ក៏ដូចជាការស្ដារមកវិញនូវការថយចុះតម្លៃនោះ។

(ខ) ការរៀបចំរចនាសម្ព័ន្ធឡើងវិញនៃសកម្មភាពរបស់អង្គភាព និងការស្ដារឡើងវិញនៃ សំវិធានធន សម្រាប់ថ្លៃដើមនៃការរៀបចំរចនាសម្ព័ន្ធឡើងវិញ។

(គ) ការលក់បញ្ចេញចោលនូវទ្រព្យ រោងចក្រ និងបរិក្ខា។

(ឃ) ការលក់បញ្ចេញចោលនូវវិនិយោគ។

(ង) ប្រតិបត្តិការមិនបន្ត។

(ច) ការដោះស្រាយវិវាទ និង

(ឆ) ការស្ដារឡើងវិញនូវសំវិធានធនដទៃទៀត។

៩៩ អង្គភាពត្រូវបង្ហាញអំពី ការវិភាគលើចំណាយ ដែលបានទទួលស្គាល់ក្នុងចំណេញ ឬខាត ដោយប្រើការចាត់ថ្នាក់ផ្អែកលើមូលដ្ឋាន ទាំងប្រភេទ

របស់វា និងទាំងតួនាទីរបស់វាក្នុងអង្គភាព ដែលផ្តល់ ព័ត៌មានគួរឱ្យទុកចិត្ត និងកាន់តែមានភាពពាក់ព័ន្ធ។

១០០ អង្គភាពនានា ត្រូវបានលើកទឹកចិត្តឱ្យបង្ហាញនូវការវិភាគដែលមានចែងនៅកថាខណ្ឌ ៩៩ ក្នុងរបាយការណ៍ស្តីពីចំណូលបន្ទាប់បន្សំ ឬក្នុងរបាយ-ការណ៍លទ្ធផលដាច់ដោយឡែក (ប្រសិនត្រូវបានបង្ហាញ)។

១០១ ចំណាយ ដែលត្រូវបានចាត់ជាចំណាត់ថ្នាក់រង ដើម្បីបង្ហាញនូវសមាសធាតុនៃប្រតិបត្តិការហិរញ្ញវត្ថុដែលអាចមានភាពខុសគ្នា លើភាពញឹកញាប់សក្តានុពលនៃចំណេញ ឬខាត និងលើភាពដែលអាចព្យាករណ៍បាន។ ការវិភាគនេះ ត្រូវបានផ្តល់ជូនតាមទម្រង់មួយក្នុងចំណោមទម្រង់ពីរ។

១០២ ទម្រង់ទី ១ នៃការវិភាគ គឺ វិធីសាស្ត្រនៃ "ប្រភេទចំណាយ"។ អង្គភាពសរុបចំណាយនៅក្នុងចំណេញឬខាតស្របតាមប្រភេទរបស់វា(ឧទាហរណ៍ ដូចជា ការកាត់រំលោះ ការទិញសម្ភារៈ ថ្លៃដើមដឹកជញ្ជូន អត្ថប្រយោជន៍បុគ្គលិក និងថ្លៃដើមផ្សាយពាណិជ្ជកម្ម) និងមិនបានធ្វើវិភាជន៍ឡើងវិញនូវចំណាយទាំងនោះឱ្យមានតួនាទីនៅក្នុងអង្គភាព។ វិធីសាស្ត្រនេះ មានលក្ខណៈងាយស្រួលក្នុងការអនុវត្តពីព្រោះមិនមានការធ្វើវិភាជន៍ចំណាយតាមចំណាត់ថ្នាក់តួនាទី ជាការចាំបាច់ទេ។ ឧទាហរណ៍នៃការធ្វើចំណាត់ថ្នាក់ដោយប្រើវិធីសាស្ត្រប្រភេទចំណាយ មានដូចខាងក្រោម :

| | | | |
|---|---|---|---|
| | ចំណូល | | X |
| | ចំណូលដទៃទៀត | | X |
| | ការប្រែប្រួលនៃសន្និធិផលិតផលសម្រេចនិងផលិតផលមិនទាន់សម្រេច | | |
| | វត្ថុធាតុដើមនិងសម្ភារៈដែលបានប្រើប្រាស់ | | |

| | | | |
|---|---|---|---|
| | ចំណាយសម្រាប់អត្ថប្រយោជន៍បុគ្គលិក | | |
| | ចំណាយលើការដករំលោះនិងការរំលោះ | | |
| | ចំណាយផ្សេងៗ | | |
| | ចំណាយសរុប | | (X) |
| | ចំណេញមុនបង់ពន្ធ | | X |

១០៣ ទម្រង់ទី ២ នៃការវិភាគគឺ វិធីសាស្ត្រ “តួនាទីចំណាយ” ឬវិធីសាស្ត្រ “ថ្លៃលក់” ហើយចាត់ថ្នាក់ចំណាយស្របតាមតួនាទីរបស់វា ឧទាហរណ៍ចាត់ថាជាផ្នែកមួយនៃថ្លៃលក់ ឬថ្លៃចែកចាយ ឬចំណាយសកម្មភាពរដ្ឋបាល។ យ៉ាងហោចណាស់អង្គភាពលាតត្រដាងអំពីថ្លៃដើមលក់តាមវិធីសាស្ត្រនេះដាច់ដោយឡែកពីចំណាយដទៃទៀត។ វិធិសាស្ត្រនេះ ផ្តល់ព័ត៌មានកាន់តែពាក់ព័ន្ធដល់អ្នកប្រើប្រាស់ជាងការចាត់ថ្នាក់ចំណាយតាមប្រភេទ ប៉ុន្តែការធ្វើវិភាជន៍ថ្លៃដើមទៅរកតួនាទី អាចតម្រូវឱ្យធ្វើវិភាជន៍តាមចិត្តហើយពាក់ព័ន្ធនឹងការសម្រេចចិត្តចាំបាច់។ ឧទាហរណ៍នៃ ការធ្វើចំណាត់ថ្នាក់ដោយប្រើវិធីសាស្ត្រចំណាយតាមតួ:

| | | | |
|---|---|---|---|
| | ចំណូល | | |
| | ថ្លៃដើមលក់ | (X) | |
| | ចំណេញដុល | | |
| | ចំណូលដទៃទៀត | | |
| | ថ្លៃដើមចែកចាយ | (X) | |

| | | | |
|---|---|---|---|
| | ចំណាយរដ្ឋបាល | (X) | |
| | ចំណាយផ្សេងៗ | (X) | |
| | ប្រាក់ចំណេញមុនបង់ពន្ធ | | |

១០៤ អង្គភាពដែលចាត់ថ្នាក់ចំណាយតាមតួនាទី ត្រូវលាតត្រដាងព័ត៌មានបន្ថែមអំពីប្រភេទចំណាយរួមបញ្ចូលទាំងចំណាយដករំលោះនិងចំណាយរំលោះព្រមទាំងចំណាយអត្ថប្រយោជន៍បុគ្គលិក។

១០៥ ការជ្រើសរើសរវាងវិធីសាស្រ្តចំណាតាមតួនាទី និងវិធីសាស្រ្តចំណាយតាមប្រភេទ គឺអាស្រ័យលើកត្តាប្រវត្តិសាស្រ្តនិងកត្តាឧស្សាហកម្ម ព្រមទាំងប្រភេទនៃអង្គភាព។ វិធីសាស្រ្តទាំងពីរនេះ ផ្តល់នូវការចង្អុលបង្ហាញនៃថ្លៃដើមទាំងនោះដែលអាចប្រែប្រួលដោយផ្ទាល់ឬដោយប្រយោលតាមកម្រិតនៃការលក់ ឬការផលិតរបស់អង្គភាព។ ដោយសារតែវិធីសាស្រ្តនីមួយៗនៃការបង្ហាញមានភាព សមស្របជាមួយនឹងប្រភេទអង្គភាពផ្សេងៗគ្នា ស្តង់ដានេះ តម្រូវឱ្យអ្នកគ្រប់គ្រង ជ្រើសរើសការបង្ហាញដែលគួរឱ្យទុកចិត្តនិងកាត់តែមានភាពពាក់ព័ន្ធ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែព័ត៌មានស្តីពីប្រភេទនៃចំណាយមានប្រយោជន៍ក្នុងការព្យាករណ៍លំហូរសាច់ប្រាក់នាពេលអនាគត ការលាតត្រដាងព័ត៌មានបន្ថែមទៀតត្រូវបានតម្រូវនៅពេលដែលការចាត់ថ្នាក់តាមតួនាទីរបស់ ចំណាយត្រូវបានប្រើប្រាស់។ ក្នុងកថាខណ្ឌ ១០៤ “អត្ថប្រយោជន៍បុគ្គលិក” មានអត្ថន័យដូចក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ១៩ ដែរ។

## របាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់

## ព័ត៌មានដែលត្រូវបង្ហាញក្នុងបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់

១០៦ អង្គភាពត្រូវបង្ហាញរបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ ដូចដែលបានតម្រូវដោយកថាខណ្ឌ ១០។ របាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ រួមមានព័ត៌មានដូចខាងក្រោម :

(ក) ចំណូលបន្ទាប់បន្សំសរុបសម្រាប់ការិយបរិច្ឆេទ ដោយបង្ហាញដាច់ដោយឡែកនូវ បរិមាណទឹកប្រាក់សរុប ដែលអាចផ្តល់ជូនម្ចាស់ហ៊ុននៃក្រុមហ៊ុនមេ ឬផ្តល់ចំពោះភាគកម្មដែលមិនមានសិទ្ធិត្រួតពិនិត្យ។

(ខ) អានុភាពប្រតិសកម្មនៃការអនុវត្តប្រតិសកម្ម ឬការរាយការណ៍ឡើងវិញនៃធាតុនិមួយៗនៃមូលធនផ្ទាល់ ដែលបានទទួលស្គាល់ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិ ៨ និង

(គ) (លុបចោល)

(ឃ) ការផ្ទៀងផ្ទាត់រវាងតម្លៃក្នុងបញ្ជីនាដើមនិងតម្លៃក្នុងបញ្ជីរបស់សមាសធាតុនីមួយៗនៃមូលធនផ្ទាល់ នាដើមនិងចុងការិយបរិច្ឆេទ ដោយលាតត្រដាងដាច់ដោយឡែកពីគ្នា នូវការប្រែប្រួលដែលបណ្តាលមកពី :

១- ចំណេញឬខាត

២- ចំណូលបន្ទាប់បន្សំដទៃទៀត និង

៣- ប្រតិបត្តិការជាមួយ ម្ចាស់ហ៊ុន ក្នុងសមត្ថភាពជាម្ចាស់ហ៊ុនដោយបង្ហាញដាច់ដោយឡែកអំពី វិភាគទានទទួលបានពី ឬវិភាគទាន

ដែលត្រូវបង់ជូនម្ចាស់ហ៊ុន ព្រមទាំងការប្រែប្រួលនានាលើភាគកម្ម កម្មសិទ្ធិក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិនបណ្តាលឱ្យបាត់បង់ការត្រួតពិនិត្យ។

## ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ ឬក្នុងកំណត់សម្គាល់

១០៦ក សម្រាប់ធាតុនិមួយៗនៃមូលធនផ្ទាល់ អង្គភាពត្រូវបង្ហាញទាំងក្នុងរបាយ-ការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ និងទាំងក្នុងកំណត់សម្គាល់នូវការវិភាគលើចំណុលបន្ទាប់បន្សំដទៃទៀត (សូមមើលកថាខណ្ឌ ១០៦ (ឃ ២))។

១០៧ អង្គភាពត្រូវបង្ហាញទាំងក្នុងរបាយការណ៍ស្តីពី ការប្រែប្រួលមូលធនផ្ទាល់ និងទាំងក្នុងកំណត់សម្គាល់ នូវបរិមាណភាគលាភដែលបានទទួលស្គាល់ថាជា វិភាគទានដែលត្រូវផ្តល់ដល់ម្ចាស់ហ៊ុនក្នុងកំឡុងការិយបរិច្ឆេទព្រមទាំងអំពីបរិមាណភាគលាភដែលពាក់ព័ន្ធក្នុងមួយសន្លឹកហ៊ុន។

១០៨ ក្នុងកថាខណ្ឌ ១០៦ សមាសធាតុនៃមូលធនផ្ទាល់ ឧទាហរណ៍រួមមានថ្នាក់និមួយៗនៃមូលធនផ្ទាល់ដែលបានផ្តល់ សមតុល្យបូកយោងនៃថ្នាក់និមួយៗនៃចំណូលបន្ទាប់បន្សំដទៃទៀតព្រមទាំងប្រាក់ចំណេញរក្សាទុក។

១០៩ ការប្រែប្រួលនៃមូលធនផ្ទាល់របស់អង្គភាពរវាងការប្រែប្រួលនាដើម និងចុងការិយបរិច្ឆេទរាយការណ៍ បង្ហាញនូវការកើនឡើង ឬថយចុះនៃទ្រព្យសកម្មសុទ្ធរបស់ខ្លួនក្នុងកំឡុងការិយបរិច្ឆេទ។ លើកលែងតែការប្រែប្រួលដែលជាលទ្ធផលនៃ ប្រតិបត្តិការជាមួយម្ចាស់ហ៊ុន (ដូចជាវិភាគទាន ជាមូលធនផ្ទាល់ ការទទួលបានមកវិញនូវឧបករណ៍មូលធនផ្ទាល់របស់ អង្គ

ភាព និងភាគលាភ) ព្រមទាំងថ្លៃដើមប្រតិបត្តិការដែលទាក់ទងដោយផ្ទាល់ទៅនឹងប្រតិបត្តិការនេះ ការប្រែប្រួលរួមនៃមូលធនផ្ទាល់ក្នុងកំឡុងការិយបរិច្ឆេទ បង្ហាញឡើងវិញនូវចំនួនសរុបនៃចំណូលនិងចំណាយ រួមទាំងចំណេញនិងខាតដែលទទួលបានពីសកម្មភាពរបស់អង្គភាពក្នុងកំឡុងការិយបរិច្ឆេទនោះ។

១១០ ស្តង់ដាគណនេយ្យ ៨ តម្រូវឱ្យមានការកែតម្រូវប្រតិសកម្ម នាំឱ្យមាន ឥទ្ធិពលលើការប្រែប្រួលគោលនយោបាយ បើអាចអនុវត្តបានលើកលែង តែនៅពេលដែលវិធានអន្តរកាលនៅក្នុង ស្តង់ដារបាយការណ៍ ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត តម្រូវផ្ទុយពីនេះ។ ស្តង់ដាគណនេយ្យ ៨ ក៏បានតម្រូវផងដែរឱ្យរាយការណ៍ឡើងវិញ ដើម្បីកែតម្រូវកំហុសឆ្គង ដែលត្រូវធ្វើដោយប្រតិសកម្ម ប្រសិនបើអាចធ្វើទៅបាន។ ការកែតម្រូវប្រតិសកម្ម និងការរាយការណ៍ឡើងវិញដោយប្រតិសកម្ម មិននាំឱ្យមាន ការប្រែប្រួលលើមូលធនផ្ទាល់ ប៉ុន្តែវាជាការកែតម្រូវសមតុល្យដើមគ្រា របស់ប្រាក់ចំណេញរក្សាទុក លើកលែងតែនៅពេលដែលស្តង់ដារបាយ-ការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិតម្រូវឱ្យមានការកែតម្រូវប្រតិសកម្មលើសមាសធាតុរបស់មូលធនផ្ទាល់ផ្សេងទៀត។ កថាខណ្ឌ ១០៦ (ខ) តម្រូវឱ្យលាតត្រដាងព័ត៌មានអំពីរបាយការណ៍ ស្តីពីការប្រែប្រួលមូលធនផ្ទាល់នៃការកែតម្រូវសរុបលើសមាសធាតុនិមួយៗនៃមូលធនផ្ទាល់ដែលបណ្តាលមកពីការប្រែប្រួលគោលនយោបាយគណនេយ្យនិងបណ្តាលមកពីការកែតម្រូវកំហុសឆ្គងដាច់ដោយឡែកពីគ្នា។ ការកែតម្រូវទាំងនេះត្រូវបានលាតត្រដាងសម្រាប់ការិយបរិច្ឆេទនិមួយៗមុនៗ និងនាដើមការិយ-បរិច្ឆេទ។

**របាយការណ៍អំពីលំហូរសាច់ប្រាក់**

១១១ ព័ត៌មានលំហូរសាច់ប្រាក់ផ្តល់ដល់អ្នកប្រើប្រាស់នូវរបាយការណ៍ហិរញ្ញវត្ថុជាមួយមូលដ្ឋានមួយ ដើម្បីវាយតម្លៃលើ លទ្ធភាពរបស់អង្គភាពក្នុងការប្រមូលសាច់ប្រាក់និងសាច់ប្រាក់ប្រហែល ព្រមទាំងវាយតម្លៃអំពី សេចក្តីត្រូវការរបស់អង្គភាពក្នុងការប្រើប្រាស់លំហូរសាច់ប្រាក់ទាំងនោះ។ ស្តង់ដាគណនេយ្យអន្តរជាតិ ៧ កំណត់នូវតម្រូវការក្នុងការបង្ហាញ និងការលាតត្រដាងព័ត៌មានអំពីលំហូរសាច់ប្រាក់។

**<u>កំណត់សម្គាល់</u>**

**រចនាសម្ព័ន្ធ**

១១២ កំណត់សម្គាល់ត្រូវ :

(ក) បង្ហាញព័ត៌មានអំពី មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងគោលនយោបាយគណនេយ្យដោយឡែក ដែលបានប្រើប្រាស់ស្របតាមកថាខណ្ឌ ១១៧-១២៤។

(ខ) លាតត្រដាងព័ត៌មាន ដែលតម្រូវដោយ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលមិនត្រូវបានបង្ហាញនៅកន្លែងណាមួយក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(គ) ផ្តល់នូវព័ត៌មានដែលមិនបានបង្ហាញនៅកន្លែងណាមួយនៃរបាយ-ការណ៍ហិរញ្ញវត្ថុ ប៉ុន្តែពាក់ព័ន្ធដល់ការយល់ដឹង អំពីព័ត៌មាននោះទេ។

១១៣ ដរាបណាអាចអនុវត្តបាន អង្គភាពត្រូវបង្ហាញកំណត់សម្គាល់ជាលក្ខណៈប្រព័ន្ធ។ អង្គភាពត្រូវយោងធាតុនិមួយៗ ក្នុងរបាយការណ៍ស្តីពីស្ថានភាព

ហិរញ្ញវត្ថុ និងរបាយការណ៍ស្តីពី ចំណូលបន្ទាប់បន្សំនៅក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែក (បើត្រូវបានបង្ហាញ) ព្រមទាំងនៅក្នុងរបាយ-ការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ និងរបាយការណ៍នៃលំហូរសាច់ប្រាក់ចំពោះព័ត៌មានពាក់ព័ន្ធដទៃទៀតក្នុងកំណត់សម្គាល់។

១១៤ ជាធម្មតា អង្គភាពបង្ហាញ កំណត់សម្គាល់តាមលំដាប់លំដោយដូចខាងក្រោម ដើម្បីជួយដល់អ្នកប្រើប្រាស់ យល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុ និងប្រៀបធៀបព័ត៌មានទាំងនោះជាមួយ របាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាពផ្សេងៗទៀត។

(ក) របាយការណ៍ស្តីពី អនុលោមភាពទៅនឹង ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (សូមមើលកថាខណ្ឌ ១៦)

(ខ) សេចក្តីសង្ខេបអំពី គោលនយោបាយគណនេយ្យសំខាន់ៗដែលបានអនុវត្ត (សូមមើលកថាខណ្ឌ ១១៧)

(គ) ព័ត៌មានគាំទ្រធាតុនានា ដែលបានបង្ហាញក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនិងរបាយការណ៍ចំណូលបន្ទាប់បន្សំដែលបានបង្ហាញនៅក្នុងរបាយការណ៍ លទ្ធផលលាច់ដោយឡែក (ប្រសិនបើវាតម្រូវបានបង្ហាញ) និងនៅក្នុងរបាយការណ៍ស្តីពី ការប្រែប្រួលមូលធនផ្ទាល់ និងរបាយការណ៍ស្តីពីលំហូរសាច់ប្រាក់តាមលំដាប់លំដោយ ដែលក្នុងនោះរបាយការណ៍និមួយៗ និងធាតុពាក់ព័ន្ធ និមួយៗ ត្រូវបានបង្ហាញ និង

(ឃ) ការលាតត្រដាងព័ត៌មានដទៃទៀត ដែលរួមមាន :

១- បំណុលយថាហេតុ (សូមមើលស្តង់ដាគណនេយ្យ អន្តរជាតិ ៣៧) និងការសន្មតាតាមកិច្ចសន្យាដែលមិនត្រូវបានទទួលស្គាល់។

២-ការលាតត្រដាងព័ត៌មានមិនមែនហិរញ្ញវត្ថុ មានដូចជាហានិភ័យហិរញ្ញវត្ថុរបស់ អង្គភាព គោលដៅរបស់អ្នកគ្រប់គ្រង និងគោលនយោបាយនានា (សូមមើលស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧)។

១១៥ ក្នុងកាលទេសៈខ្លះអង្គភាពអាចមានការចាំបាច់ឬមានបំណងចង់ធ្វើឱ្យមានការប្រែប្រួល នៃលំដាប់លំដោយ នៃធាតុដោយឡែកៗ នៅក្នុងកំណត់ សម្គាល់។ ឧទាហរណ៍ អង្គភាពអាចបញ្ចូលនូវព័ត៌មានស្តីពីការប្រែប្រួលតម្លៃទីផ្សារ ដែលត្រូវបានទទួលស្គាល់ នៅក្នុងចំណេញ ឬខាត ជាមួយនឹងព័ត៌មានអំពីការដល់កាល កំណត់សងរបស់ឧបករណ៍ហិរញ្ញវត្ថុទោះបីជាការលាតត្រដាងព័ត៌មាន ពីពេលមុនទាក់ទិនដល់ របាយការណ៍ស្តីពីចំណូលបន្ទាប់បន្សំ ឬដល់របាយការណ៍លទ្ធផលដាច់ដោយឡែក (បើត្រូវបានបង្ហាញ) ហើយក្រោយមកទាក់ទិននឹងរបាយការណ៍ស្តីពី ស្ថានភាពហិរញ្ញវត្ថុក៏ដោយ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គភាពថែរក្សានូវរចនាសម្ព័ន្ធជាប្រព័ន្ធសម្រាប់កំណត់សម្គាល់ដរាបណាវាអាចធ្វើទៅបាន។

១១៦ អង្គភាពអាចបង្ហាញ កំណត់សម្គាល់នានាដោយផ្តល់នូវ ព័ត៌មានអំពី មូលដ្ឋាន ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយ ពិសេសៗ ជាផ្នែកដាច់ដោយឡែកមួយនៃ របាយការណ៍ហិរញ្ញវត្ថុ។

## ការលាតត្រដាងអំពីគោលនយោបាយគណនេយ្យ

១១៧ អង្គភាពត្រូវលាតត្រដាងអំពីសេចក្តីសង្ខេបនៃគោលនយោបាយសំខាន់ៗ:

(ក) មូលដ្ឋានក្នុងការវាស់វែង (ឬមូលដ្ឋានច្រើន) ដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និង

(ខ)គោលនយោបាយគណនេយ្យដទៃទៀតដែលបានប្រើ ពាក់ព័ន្ធ នឹង ការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុ។

១១៨ វាមានសារសំខាន់ណាស់ចំពោះអង្គភាពក្នុងការផ្តល់ព័ត៌មាន ដល់អ្នកប្រើប្រាស់អំពីមូលដ្ឋាននៃ ការវាស់វែង ឬមូលដ្ឋាននានា ដែលបានប្រើក្នុងរបាយការណ៍ហិរញ្ញវត្ថុ (ឧទាហរណ៍ ថ្លៃដើមប្រវត្តិសាស្រ្ត ថ្លៃដើមមុនៗ តម្លៃសុទ្ធដែលអាចស្តារមកវិញបាន តម្លៃទីផ្សា ឬបរិមាណទឹកប្រាក់ដែលអាចទទួលបានមកវិញ) មូលដ្ឋានដែលអង្គភាពយកមករៀបចំរបាយការណ៍ហិរញ្ញវត្ថុ មានផលប៉ះពាល់ខ្លាំងដល់ការវិភាគរបស់អ្នកប្រើប្រាស់។ នៅពេលដែលអង្គភាពប្រើមូលដ្ឋានក្នុងការវាយតម្លៃលើសពីមួយ ក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុ ឧទាហរណ៍ ដូចជានៅពេលដែលមានថ្នាក់នៃទ្រព្យសកម្មត្រូវបានវាយតម្លៃឡើងវិញ ដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការផ្តល់នូវការចង្អុលបង្ហាញអំពី ប្រភេទនានានៃទ្រព្យសកម្ម និងបំណុលដែលមានមូលដ្ឋានក្នុងការវាស់វែងត្រូវបានអនុវត្ត។

១១៩ ក្នុងការសម្រេច ថាតើគោលនយោបាយគណនេយ្យពិសេសណាមួយត្រូវបានលាតត្រដាង ឬអត់នោះ អ្នកគ្រប់គ្រងត្រូវពិចារណាថាតើការលាតត្រដាងអាចជួយអ្នកប្រើប្រាស់យល់ដឹងថា តើប្រតិបត្តិការព្រឹត្តិការណ៍និងលក្ខខណ្ឌនានា ត្រូវបានបង្ហាញយ៉ាងដូចម្តេច ក្នុងប្រតិបត្តិការហិរញ្ញវត្ថុ និងស្ថានភាពហិរញ្ញវត្ថុ ដែលបានរាយការណ៍ ។ ការលាតត្រដាងអំពីគោលនយោបាយគណនយ្យដោយឡែក គឺជាពិសេស មានប្រយោជន៍ចំពោះអ្នកប្រើប្រាស់ នៅពេលដែលគោលនយោបាយនោះ ត្រូវបានជ្រើសរើសពីជម្រើសនានាដែលអនុញ្ញាតក្នុង ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ។ឧទាហរណ៍មួយការលាតត្រដាងថាតើអ្នកដាក់ទុន

រួមគ្នាទទួលស្គាល់ភាគកម្មរបស់ខ្លួនក្នុង អង្គភាពត្រួតពិនិត្យរួមគ្នាដោយប្រើការរួមបញ្ចូលសមាមាត្រ ឬដោយប្រើវិធីសាស្ត្រមូលធនផ្ទាល់ ឬទេ (សូមមើលស្តង់ដាគណនេយ្យអន្តរជាតិ ៣១ ស្តីពី *ភាគកម្មនៅក្នុង ក្រុមហ៊ុនរួមទុន*)។ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិខ្លះតម្រូវជាពិសេសឱ្យលាតត្រដាងគោលនយោបាយគណនេយ្យ រួមបញ្ចូលទាំងជម្រើសដែលអ្នកគ្រប់គ្រងបានសម្រេចយក រវាងគោលនយោបាយដែលស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ អនុញ្ញាត ។ ឧទាហរណ៍ ស្តង់ដាគណនេយ្យអន្តរជាតិ ១៦ តម្រូវឱ្យលាតត្រដាងអំពីមូលដ្ឋាននៃការវាស់វែងដែលបានប្រើប្រាស់សម្រាប់ទ្រព្យ រោងចក្រ និងបរិក្ខា។

១២០ អង្គភាពនិមួយៗ ត្រូវពិចារណាអំពីប្រភេទនៃប្រតិបត្តិការរបស់ខ្លួន និងគោលនយោបាយនានាដែលអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុអាចរំពឹងថានឹងទទួលបាន ការលាតត្រដាង សម្រាប់អង្គភាពគ្រប់ប្រភេទ។ ឧទាហរណ៍ ដូចជាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល អ្នកប្រើប្រាស់អាចរំពឹងថាអង្គភាពនឹងទទួលបាន ការលាតត្រដាងព័ត៌មានអំពីគោលនយោបាយគណនេយ្យរបស់ អង្គភាព ចំពោះពន្ធលើប្រាក់ចំណូល រួមទាំងគោលនយោបាយ ដែលអាចអនុវត្តចំពោះបំណុលនិងទ្រព្យសកម្មជាពន្ធពន្យា។ នៅពេលដែលអង្គភាពមួយមានប្រតិបត្តិការក្រៅប្រទេសចម្បងៗ ឬមានប្រតិបត្តិការជារូបិយប័ណ្ណបរទេស អ្នកប្រើប្រាស់អាចរំពឹងថានឹងមានការលាតត្រដាង ព័ត៌មានអំពី គោលនយោបាយគណនេយ្យសម្រាប់ទទួលស្គាល់ចំណេញឬខាតដែលបានពីការប្តូរប្រាក់បរទេស។

១២១ គោលនយោបាយគណនេយ្យមួយអាចមានសារសំខាន់ដោយសារប្រភេទប្រតិបត្តិការរបស់អង្គភាព ទោះបីជាបរិមាណទឹកប្រាក់នាការិយបរិច្ឆេទបច្ចុប្បន្ន និងសម្រាប់ការិយបរិច្ឆេទមុនៗ មិនមានលក្ខណៈជាសារវន្តក៏ដោយ។ វាក៏មានភាពត្រឹមត្រូវផងដែរក្នុងការលាតត្រដាងព័ត៌មានស្តីអំពីគោលនយោបាយសំខាន់និមួយៗ ទោះបីមិនមានការតម្រូវជាពិសេសក៏ដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ប៉ុន្តែអង្គភាពបានជ្រើសរើស និងអនុវត្ត ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិ ៨។

១២២ នៅក្នុងសេចក្តីសង្ខេប នៃគោលនយោបាយគណនេយ្យសំខាន់ៗ ឬក្នុងកំណត់សម្គាល់ផ្សេងទៀត អង្គភាពត្រូវលាតត្រដាងអំពី សេចក្តីសម្រេចដែលអ្នកគ្រប់គ្រងបានធ្វើឡើង ក្នុងការដំណើរការអនុវត្តគោលនយោបាយគណនេយ្យរបស់ខ្លួន ក្រៅពីសេចក្តី សម្រេចពាក់ព័ន្ធនឹង ការប៉ាន់ស្មាន (សូមមើលកថាខណ្ឌ ១២៥) ព្រមទាំងសេចក្តីសម្រេច ដែលមានឥទ្ធិពលខ្លាំងបំផុតលើបរិមាណទឹកប្រាក់ ដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

១២៣ ក្នុងដំណើរការអនុវត្ត គោលនយោបាយគណនេយ្យ របស់អង្គភាពក្រៅពីសេចក្តីសម្រេចទាក់ទិននឹងការប៉ាន់ស្មានអ្នកគ្រប់គ្រងធ្វើសេចក្តីសម្រេចចិត្តផ្សេងៗដែលអាចជះឥទ្ធិពលខ្លាំងលើបរិមាណទឹកប្រាក់ដែលអ្នកគ្រប់គ្រងទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ឧទាហរណ៍ អ្នកគ្រប់គ្រងធ្វើសេចក្តីសម្រេចចិត្ត ក្នុងការកំណត់ៈ

(ក)(លុបចោល)

(ខ) នៅពេលដែលហានិភ័យសំខាន់ៗទាំងអស់ និងប្រាក់រង្វាន់នៃភាពជាកម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុនិង ទ្រព្យសកម្មភតិសន្យាត្រូវបានផ្ទេរទៅអង្គភាពដទៃទៀត។

(គ) ថាតើការលក់ទំនិញពិសេស បានធ្វើហិរញ្ញប្បទាន តាមកិច្ចសន្យាហើយមិននាំឱ្យមានចំណូលឬយ៉ាងណា និង

(ឃ) ថាតើទំនាក់ទំនងចម្បងរវាងអង្គភាពនិងអង្គភាពដែលមានគោលបំណងពិសេសបង្ហាញថាអង្គភាពត្រួតពិនិត្យលើអង្គភាពដែលមានគោលបំណងពិសេសឬទេ។

១២៤ ការលាតត្រដាងព័ត៌មានខ្លះ ត្រូវបានធ្វើឡើងស្របតាមកថាខណ្ឌ ១២២ ត្រូវបានតម្រូវដោយ ស្តង់ដារបាយការណ៍ទាក់ទងទៅនឹងហិរញ្ញវត្ថុ អន្តរជាតិដទៃទៀត ។ ឧទាហរណ៍ ស្តង់ដាគណនេយ្យអន្តរជាតិ ២៧ តម្រូវឱ្យអង្គភាពលាតត្រដាងអំពីហេតុផល ថាតើហេតុអ្វីបានជាភាគកម្ម សិទ្ធិរបស់អង្គភាពមិននាំឱ្យមានការត្រួតពិនិត្យ ចំពោះអង្គភាព ដែលគេ ដាក់ទុនវិនិយោគជាមួយ ដែលមិនមែនជាក្រុមហ៊ុនញាតិសម្ព័ន្ធ ទោះបី ជាសិទ្ធិបោះឆ្នោត ឬអំណាចបោះឆ្នោតសក្តានុពលជាងពាក់កណ្តាលត្រូវ បានកាន់កាប់ដោយផ្ទាល់ឬដោយប្រយោល តាមរយៈក្រុមហ៊ុនញាតិសម្ព័ន្ធ ក៏ដោយ។ ស្តង់ដាគណនេយ្យអន្តរជាតិ ៤០ ស្តីពី *ទ្រព្យវិនិយោគ* តម្រូវ ឱ្យលាតត្រដាងអំពីលក្ខណៈវិនិច្ឆ័យ ដែលបង្កើតឡើងដោយអង្គភាពដើម្បី ញែកឱ្យដាច់នូវទ្រព្យវិនិយោគពីទ្រព្យសម្បត្តិ ដែលកាន់កាប់ដោយម្ចាស់ ហ៊ុន និងពីទ្រព្យសម្បត្តិដែលរក្សាទុកសម្រាប់លក់ នៅក្នុងសកម្មភាព អាជីវកម្មធម្មតា នៅពេលដែលការធ្វើចំណាត់ថ្នាក់ទ្រព្យមានការពិបាក។

**ប្រភពក្នុងការប៉ាន់ស្មានភាពមិនប្រាកដប្រជា**

១២៥ អង្គភាព ត្រូវលាតត្រដាងព័ត៌មានអំពី ការសន្មត់នានាដែលអង្គភាពធ្វើ លើអនាគត និងអំពីប្រភពប៉ាន់ស្មានដទៃទៀតលើភាពមិនប្រាកដប្រជា នាចុងការិយបិច្ឆេទរាយកាណ៍ ហើយដែលមានហានិភ័យខ្លាំងជាហេតុធ្វើ ឱ្យមានការកែតម្រូវជាសារវន្តលើតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំសារពើពន្ធបន្ទាប់។ចំពោះទ្រព្យសកម្ម និងបំណុលទាំងនោះត្រូវដាក់បញ្ចូលក្នុងកំណត់សម្គាល់នូវព័ត៌មានលម្អិតនៃ :

(ក) ប្រភេទនៃទ្រព្យនិងបំណុល និង

(ខ) តម្លៃក្នុងបញ្ជីរបស់ទ្រព្យ និងបំណុល នាចុងការិយបរិច្ឆេទរាយ-ការណ៍។

១២៦ ក្នុងការកំណត់អំពី តម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្ម និងបំណុលមួយចំនួនតម្រូវឱ្យមានការប៉ាន់ស្មានអំពី ឥទ្ធិពលនៃព្រឹត្តិការណ៍អនាគតដែលមិនប្រាកដប្រជា លើទ្រព្យ និងបំណុលទាំងនោះ នាចុងការិយបរិច្ឆេទរាយ-ការណ៍។ ឧទាហរណ៍ នៅពេលដែលគ្មានតម្លៃទីផ្សារបានពីការអង្កេតថ្មីៗ ការប៉ាន់ស្មានដៅទៅរកអនាគត គឺមានសារសំខាន់ណាស់ក្នុងការវាស់វែងបរិមាណថ្នាក់នៃទ្រព្យ រោងចក្រ និងបរិក្ខាដែលអាចស្តារមកវិញបាន។ ការវាស់វែងឥទ្ធិពលនៃភាពហួសសម័យខាងបច្ចេកវិទ្យារបស់សន្និធិ ការវាស់វែងលើវិធានដែលជាកម្មវត្ថុនៃលទ្ធផលអនាគតនៃវិវាទ និងការវាស់វែងលើ បំណុលអត្ថប្រយោជន៍បុគ្គលិករយៈពេលវែង ដូចជាកាតព្វកិច្ចសោធននិវត្តិ។ ការប៉ាន់ស្មានទាំងនេះ ពាក់ព័ន្ធដល់ការសន្មត់អំពីធាតុទាំងនោះ ចាជាការកែតម្រូវហានិភ័យលើលំហូរសាច់ប្រាក់ ឬលើអត្រា

អប្បហារចំពោះការប្រែប្រួលអនាគតលើបៀវត្ស និងចំពោះការប្រែប្រួលអនាគតនៃថ្លៃដែលប៉ះពាល់ដល់ថ្លៃដើមដទៃទៀត។

១២៧ ការសន្មត់ និងប្រភពដទៃទៀតនៃការប៉ាន់ស្មានភាពមិនប្រាកដប្រជាបានលាតត្រដាងស្របតាមកថាខណ្ឌ ១២៥ ទាក់ទិននឹងការប៉ាន់ស្មាន ដែលតម្រូវឱ្យការសម្រេចចិត្តរបស់ អ្នកគ្រប់គ្រងមានការពិបាក ឬស្មុកស្មាញបំផុត។ ដោយសារតែចំនួននៃអថេរនិងការសន្មត់ ដែលផលប៉ះពាល់ដល់ដំណោះស្រាយកំណើននៃភាពមិនប្រាកដប្រជានាអនាគតដែលអាចកើតមាន ធ្វើឱ្យសេចក្តីសម្រេចទាំងនោះកាន់តែសំខាន់ និងស្មុកស្មាញហើយសក្តានុពលនៃការកែតម្រូវជាសារវន្តលើតម្លៃក្នុងបញ្ជីរបស់ទ្រព្យស - កម្ម និងបំណុលជាធម្មតាកើនឡើងដូចគ្នា។

១២៨ ការលាតត្រដាងព័ត៌មានក្នុងកថាខណ្ឌ ១២៥ មិនតម្រូវឱ្យមានទេចំពោះទ្រព្យសកម្មនិងបំណុលដែលមានហានិភ័យខ្លាំង ហើយដែលតម្លៃក្នុងបញ្ជីរបស់វាអាចប្រែប្រួលជាសារវន្តក្នុងឆ្នាំសារពើពន្ធបន្ទាប់ ប្រសិនបើនាចុងការិយបរិច្ឆេទរាយការណ៍ ទ្រព្យសកម្ម និងបំណុលទាំងនោះត្រូវបានវាស់វែងតាមតម្លៃទីផ្សារ ដោយផ្អែកលើមូលដ្ឋានថ្លៃទីផ្សារ ដែលបានអង្កេតថ្មីៗ។ តម្លៃទីផ្សារនេះ អាចធ្វើឱ្យមានការប្រែប្រួលខ្លាំង នៅឆ្នាំសារពើពន្ធបន្ទាប់ ប៉ុន្តែការប្រែប្រួលនេះមិនកើតពីការសន្មត់ ឬពីប្រភពដទៃទៀតនៃការសន្មត់ភាពមិនប្រាកដប្រជា នាចុងការិយបរិច្ឆេទរាយការណ៍ទេ។

១២៩ អង្គភាពបង្ហាញនូវការលាតត្រដាងព័ត៌មានក្នុងកថាខណ្ឌ ១២៥ ក្នុងន័យជួយឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុយល់ដឹងអំពី សេចក្តីសម្រេចដែលអ្នកគ្រប់គ្រងបានធ្វើលើអនាគត និងលើប្រភពនៃការប៉ាន់ស្មានអំពីភាពមិនប្រាកដប្រជាដទៃទៀត។ ប្រភេទនិងវិសាលភាពនៃព័ត៌មានដែល

ផ្តល់ឱ្យ ប្រែប្រួលតាមប្រភេទនៃការសន្មត់ និងកាលទេសៈដទៃទៀត។ ឧទាហរណ៍ស្តីពីប្រភេទនៃការលាតត្រដាងព័ត៌មានដែលអង្គភាពធ្វើមានៈ

(ក) ប្រភេទនៃការសន្មត់ ឬការប៉ាន់ស្មាន ភាពមិនប្រាកដប្រជាដទៃទៀត។

(ខ) វេទយិតភាពនៃតម្លៃក្នុងបញ្ជីចំពោះវិធីសាស្ត្រ ការសន្មត់ និងការប៉ាន់ស្មាន ដែលជាមូលដ្ឋាននៃការគណនា ព្រមទាំងហេតុផលនានានៃវេទយិតភាព (ភាពងាយប្រែប្រួល)។

(គ) ការដោះស្រាយភាពមិនប្រាកដប្រជាដែលរំពឹងទុក និងលំដាប់លំដោយនៃលទ្ធផល ដែលអាចកើតមានយ៉ាងពិតប្រាកដក្នុងឆ្នាំសារពើពន្ធបន្ទាប់ចំពោះតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្មនិងបំណុលដែលបានទទួលឥទ្ធិពល និង

(ឃ) ការពន្យល់អំពីការប្រែប្រួល ដែលបានធ្វើចំពោះការសន្មត់ពីមុនទាក់ទិននឹងទ្រព្យសកម្មនិងបំណុលទាំងនោះ ប្រសិនបើភាពមិនប្រាកដប្រជានៅមិនទាន់បានដោះស្រាយនៅឡើយ។

១៣០ ស្តង់ដានេះ មិនតម្រូវឱ្យអង្គភាពមួយលាតត្រដាងនូវព័ត៌មាន ថវិកា ឬការព្យាករណ៍ដែលត្រូវធ្វើការលាតត្រដាង ព័ត៌មានតាម កថាខណ្ឌ ១២៥ ទេ។

១៣១ ពេលខ្លះ ការលាតត្រដាងព័ត៌មានមិនអាចធ្វើទៅបានទេ ចំពោះឥទ្ធិពលដែលអាចកើតមាននៃការសន្មត់ឬប្រភពនៃការប៉ាន់ស្មាន ភាពមិនប្រាកដប្រជាផ្សេងទៀតនាចុងការិយបរិច្ឆេទរាយការណ៍។ ក្នុងករណីនេះផ្អែកលើមូលដ្ឋាននៃការយល់ដឹង ដែលមានស្រាប់ អង្គភាពត្រូវលាតត្រដាងថា វា

ពិតជាអាចមានផលនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ ដែលខុសពីការសន្មត់ អាចតម្រូវឱ្យមានការកែតម្រូវជាសារវន្តមួយលើ តម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្ម ឬបំណុលដែលទទួលផលប៉ះពាល់។ គ្រប់ករណីទាំងអស់អង្គភាពលាតត្រដាងអំពីប្រភេទនិងតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្ម ឬបំណុលដោយឡែកមួយ (ឬថ្នាក់នៃទ្រព្យសកម្ម ឬបំណុល) ដែលទទួលរងឥទ្ធិពលពីការសន្មត់។

១៣២ ការលាតត្រដាងព័ត៌មាននៅក្នុង កថាខណ្ឌ ១២២ អំពី សេចក្តីសម្រេចពិសេស ដែលអ្នកគ្រប់គ្រងបានបង្កើតឡើងក្នុងដំណើរការអនុវត្ត គោលនយោបាយគណនេយ្យ មិនពាក់ព័ន្ធនឹងការលាតត្រដាងព័ត៌មានអំពីប្រភពនៃការប៉ាន់ស្មានភាពមិនប្រាកដប្រជាក្នុងកថាខណ្ឌ ១២៥។

១៣៣ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដទៃទៀតតម្រូវឱ្យមានការលាតត្រដាងនូវការសន្មត់ខ្លះ ដែលអាចតម្រូវផ្សេងពីនេះ ស្របតាមកថាខណ្ឌ ១២៥។ឧទាហរណ៍ក្នុងកាលទេសៈពិសេសស្តង់ដាគណនេយ្យអន្តរជាតិ ៣៧ តម្រូវឱ្យលាតត្រដាងនូវការសន្មត់សំខាន់ៗ ទាក់ទិននឹងព្រឹត្តិការណ៍នាពេលអនាគតដែលប៉ះពាល់ដល់ថ្នាក់នានានៃសំវិធានធន។ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧ តម្រូវឱ្យលាត ត្រដាព័ត៌មានអំពី ការសន្មត់សំខាន់ៗ ដែលអង្គភាពប្រើក្នុងការប៉ាន់ស្មានតម្លៃទីផ្សាររបស់ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលបានគណនាតាមតម្លៃទីផ្សារ។ ស្តង់ដាគណនេយ្យអន្តរជាតិ ១៦ តម្រូវឱ្យ លាតត្រដាងព័ត៌មានអំពី ការសន្មត់សំខាន់ៗ ដែលអង្គភាពប្រើក្នុងការ ប៉ាន់ស្មានតម្លៃទីផ្សាររបស់ធាតុនានានៃទ្រព្យ រោងចក្រ និងបរិក្ខា ដែល បានធ្វើការវាយតម្លៃឡើងវិញ។

**ដើមទុន (មូលធន)**

១៣៤ អង្គភាពត្រូវលាតត្រដាងព័ត៌មាន ដែលអាចឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃគោលដៅ គោលនយោបាយ និងដំណើរការគ្រប់គ្រងរបស់អង្គភាព។

១៣៥ ដើម្បីឱ្យស្របតាមកថាខណ្ឌ ១៣៤ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម :

(ក) ព័ត៌មានបែបគុណភាពអំពី គោលដៅ គោលនយោបាយ និងដំណើរការគ្រប់គ្រងដើមទុនរបស់អង្គភាពដែលរួមមាន :

១- ពិពណ៌នាអំពីអ្វីដែលអង្គភាពគ្រប់គ្រងជាដើមទុន។

២- ប្រភេទនៃការតម្រូវទាំងនោះ និងវិធីដែលការតម្រូវទាំងនោះត្រូវបានបញ្ចូលទៅក្នុងការគ្រប់គ្រងដើមទុន នៅពេលដែលអង្គភាពមួយត្រូវទទួលការបង្ខំពី មជ្ឈដ្ឋានខាងក្រៅនូវការតម្រូវដើមទុន និង

៣- វិធីដើម្បីសម្រេចបាន តាមគោលដៅរបស់អង្គភាព ក្នុងការគ្រប់គ្រងដើមទុន។

(ខ) សេចក្តីសង្ខេបអំពីទិន្នន័យជាតួរលេខអំពី អ្វីដែលអង្គភាពគ្រប់គ្រងជាដើមទុន។អង្គភាពមួយចំនួន ចាត់ទុកបំណុលហិរញ្ញវត្ថុខ្លះ(មានដូចជា ទម្រង់ខ្លះនៃបំណុលរងបន្ទាប់បន្សំ) ថាជាផ្នែកមួយនៃដើមទុន។ អង្គភាពដទៃទៀត ចាត់ទុកដើមទុន ជាអ្វីដែលដកចេញពីសមាសធាតុខ្លះនៃមូលធនផ្ទាល់ (មានដូចជា សមាសធាតុដែលដកចេញពីធាតុទប់ស្កាត់លំហូរសាច់ប្រាក់)។

(គ) ការប្រែប្រួលនានានៃចំណុច (ក) និង (ខ) គិតពីការិយ-បរិច្ឆេទមុនៗ។

(ឃ) ថាតើក្នុងកំឡុងការិយបរិច្ឆេទដែលអង្គភាពបំពេញតាម ការបង្ខំពីមជ្ឈដ្ឋានខាងក្រៅនូវការតម្រូវដើមទុន។

(ង) នៅពេលដែលអង្គភាពមិនបានប្រតិបត្តិតាមការបង្ខំពី មជ្ឈដ្ឋានខាងក្រៅនូវការតម្រូវដើមទុន និងផលវិបាកនៃការមិនប្រតិបត្តិតាមនេះ។

អង្គភាពផ្អែកលើមូលដ្ឋាននៃការលាតត្រដាងព័ត៌មានទាំងនេះ ដែលបានផ្តល់ដល់បុគ្គលិកជាអ្នកគ្រប់គ្រងផ្ទៃក្នុងសំខាន់ៗ។

១៣៦ អង្គភាពអាចគ្រប់គ្រងដើមទុន តាមមធ្យោបាយជាច្រើន និងត្រូវធ្វើតាមការតម្រូវផ្អែកដើមទុនខុសៗគ្នា។ ឧទាហរណ៍ ការប្រមូលផ្តុំអង្គភាពអាចបញ្ចូលអង្គភាពនានា ដែលបំពេញសកម្មភាពធានារ៉ាប់រង និងធនាគារ ហើយអង្គភាពទាំងអស់នោះអាចធ្វើប្រតិបត្តិការយុត្តាធិការជាច្រើនបាន។ នៅពេលដែលការលាតត្រដាងសរុបរួមនូវតម្រូវការមូលធន និងវិធីគ្រប់គ្រងដើមទុនដែលអាចផ្តល់ព័ត៌មានមានប្រយោជន៍ ឬនាំឱ្យបាត់បង់ការយល់ដឹងរបស់អ្នកប្រើប្រាស់លើ របាយការណ៍ហិរញ្ញវត្ថុ នៃមូលធនរបស់អង្គភាព នោះអង្គភាពត្រូវលាតត្រដាងព័ត៌មាន ដាច់ដោយឡែកពីគ្នានូវការតម្រូវផ្អែកដើមទុននិមួយៗ។

**ឧបករណ៍ហិរញ្ញវត្ថុដែលអាចលក់ដូរបាន ត្រូវបានចាត់ជាមូលធន ផ្ទាល់**

១៣៦ក សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលអាចដាក់លក់បាន ដែលត្រូវបានចាត់ជាមូលធនផ្ទាល់ អង្គភាពត្រូវលាតត្រដាងព័ត៌មាន (ចំពោះអ្វីដែលមិនបានលាតត្រដាងនៅកន្លែងណាមួយទេ) :

(ក)ទិន្នន័យជាតួរលេខសង្ខេបអំពី បរិមាណទឹកប្រាក់ដែលបានចាត់ថ្នាក់ជាមូលធនផ្ទាល់។

(ខ)គោលដៅ គោលនយោបាយរបស់អង្គភាព និងដំណើរការនៃការគ្រប់គ្រងកាតព្វកិច្ចរបស់អង្គភាពក្នុងការទិញយកវិញឬដើម្បីលោះយកឧបករណ៍ទាំងនោះ នៅពេលដែល អ្នកកាន់ឧបករណ៍នោះតម្រូវឱ្យធ្វើ រួមទាំងការប្រែប្រួលពីការិយបរិច្ឆេទមុនៗ។

(គ)លំហូរសាច់ប្រាក់ចេញតាមការសងរំលោះ ឬការទិញយកមកវិញដែលបានរំពឹងទុក នូវថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះ និង

(ឃ)ព័ត៌មានអំពីវិធីកំណត់ លំហូរសាច់ប្រាក់ចេញតាមការសងរំលោះ ឬការទិញយកមកវិញដែលបានរំពឹងទុក។

**ការលាតត្រដាងព័ត៌មានផ្សេងទៀត**

១៣៧ អង្គភាពត្រូវលាតត្រដាងព័ត៌មានៅក្នុងកំណត់សម្គាល់ :

(ក)បរិមាណនៃភាគលាភដែលបានស្នើឬបានប្រកាសមុនការ អនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនទាន់បានទទួលស្គាល់ថាជាការបែងចែកឱ្យទៅម្ចាស់ហ៊ុនក្នុងកំឡុងការិយបរិច្ឆេទព្រមទាំងបរិមាណទឹកប្រាក់ពាក់ព័ន្ធក្នុងមួយសន្លឹកហ៊ុន និង

(ខ) បរិមាណភាគលាភបុរិមា ដែលបានប្ញូកយោង ដែលមិនត្រូវបានទទួលស្គាល់។

១៣៨ ប្រសិនបើមិនបានលាតត្រដាងនៅកន្លែងណាមួយនៅក្នុងព័ត៌មាន ដែលបានបោះផ្សាយនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម :

(ក) ទីតាំង និងទម្រង់ផ្លូវច្បាប់របស់អង្គភាព ប្រទេសដែលខ្លួនធ្វើអាជីវកម្ម និងអាសយដ្ឋានដែលបានចុះបញ្ជី (ឬទីតាំងគោលនៃអាជីវកម្ម ប្រសិនបើវាខុសពីការិយាល័យដែលបានចុះបញ្ជី)។

(ខ) ការពិពណ៌នាអំពីប្រភេទប្រតិបត្តិការរបស់អង្គភាព និងសកម្មភាពចម្បងរបស់ខ្លួន។

(គ) នាមករណ៍របស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនមេចុងក្រោយ និង

(ឃ) ព័ត៌មានអំពីរយៈពេលនៃអាយុកាលរបស់អង្គភាព ប្រសិនបើអង្គភាពជាអង្គភាពមានអាយុកាលកំណត់។

## អន្តរកាល និងកាលបរិច្ឆេទចូលជាធរមាន

១៣៩ អង្គភាពត្រូវអនុវត្តស្តង់ដានេះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដោយចាប់ផ្តើមពីនៅថ្ងៃ ឬក្រោយថ្ងៃ ១ ខែ មករាឆ្នាំ ២០០៩។ ការអនុវត្តមុន ត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយ អនុម័តយកស្តង់ដានេះមុនការិយបរិច្ឆេទ អង្គភាពត្រូវរាយការណ៍អំពីករណីនេះ។

១៣៩ក ស្តង់ដាគណនេយ្យអន្តរជាតិ ២៧ (ពានវិសោធនកម្មឆ្នាំ ២០០៨) បានវិសោធនកម្មកថាខណ្ឌ១០៦។អង្គភាពត្រូវអនុវត្តវិសោធនកម្មនេះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដោយចាប់ផ្តើមនៅថ្ងៃឬបន្ទាប់ពីថ្ងៃ ១ ខែ កក្កដា

ឆ្នាំ ២០០៩។ ប្រសិនបើអង្គភាពអនុវត្តស្តង់ដា ២៧ (ដែលបានធ្វើវិសោធនកម្ម ឆ្នាំ ២០០៨) មុនការិយបរិច្ឆេទកំណត់ វិសោធនកម្មនោះត្រូវយកទៅអនុវត្តនាការិយបរិច្ឆេទមុននេះ។ វិសោធនកម្មត្រូវបានអនុវត្តប្រតិសកម្ម។

១៣៩ខ *ឧបករណ៍ហិរញ្ញវត្ថុ ដែលអាចដាក់លក់បាន និងកាតព្វកិច្ចដែលកើតពី សន្ទនីយភាព* (វិសោធនកម្មចំពោះស្តង់ដា ៣២ និងស្តង់ដា ១) ដែល បានបោះផ្សាយក្នុងខែ កុម្ភៈ ឆ្នាំ ២០០៨ បានធ្វើវិសោធនកម្មកថាខណ្ឌ ១៣៨ និងបានដាក់បញ្ចូលកថាខណ្ឌ ៨ក ៨០ក និង ១៣៦ក ។ អង្គភាពត្រូវអនុវត្តវិសោធនកម្មទាំងនេះ សម្រាប់ការិយបរិច្ឆេទ ប្រចាំឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃ ឬក្រោយថ្ងៃ ១ ខែ មករា ឆ្នាំ ២០០៩។ ការអនុវត្ត មុនត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពអនុវត្តវិសោធនកម្មទាំងនេះនា មុនការិយបរិច្ឆេទ អង្គភាពត្រូវលាតត្រដាងនូវការអនុវត្តនេះ ហើយត្រូវ អនុវត្តនូវរាល់វិសោធនកម្មទាំងអស់នៃស្តង់ដា ៣២ ស្តង់ដា ៣៩ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧ និង ការបកស្រាយ ស្តង់ដាលេខ ២ (IFRIC 2) ស្តីពី *ភាគហ៊ុនរបស់សមាជិកនៅក្នុង អង្គភាពសហប្រតិបត្តិការ និងឧបករណ៍ស្រដៀងគ្នា* នាកាលបរិច្ឆេទ ដូចគ្នា។

១៣៩គ កថាខណ្ឌ ៦៨ និង ៧១ ដែលបានធ្វើវិសោធនកម្មតាមរយៈ *ការធ្វើឱ្យប្រសើរឡើងនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ* ដែលបានបោះផ្សាយនៅខែ ឧសភា ឆ្នាំ ២០០៨។ អង្គភាពត្រូវអនុវត្តវិសោធន-កម្មទាំងអស់នោះសម្រាប់ការិយបរិច្ឆេទដើមឆ្នាំ ដោយគិតចាប់ពីថ្ងៃ ឬក្រោយថ្ងៃ ១ ខែ មករា ឆ្នាំ ២០០៩។ ការអនុវត្តមុន ត្រូវបានអនុញ្ញាត។

ប្រសិនបើ អង្គភាពមួយអនុវត្ត វិសោធនកម្មមុន ការិយបរិច្ឆេទកំណត់ អង្គភាពត្រូវលាតត្រដាងអំពីការអនុវត្តនេះ។

១៣៩ឃ កថាខណ្ឌ ៦៩ ត្រូវបានធ្វើវិសោធនកម្មតាមរយៈ *ការធ្វើឱ្យប្រសើរឡើងនូវស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ* ដែលបានបោះផ្សាយនៅខែ មេសា ឆ្នាំ ២០០៩។ អង្គភាពត្រូវអនុវត្តវិសោធនកម្មទាំងអស់នោះ សម្រាប់ការិយបរិច្ឆេទដើមឆ្នាំ ដោយគិតចាប់ពីថ្ងៃឬក្រោយថ្ងៃ ១ ខែ មករា ឆ្នាំ ២០១០។ ការអនុវត្តមុន ត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយ អនុវត្តវិសោធនកម្ម មុនការិយបរិច្ឆេទកំណត់ អង្គភាពត្រូវលាតត្រដាងអំពីការអនុវត្តនេះ។

១៣៩ង (លុបចោល)

១៣៩ច កថាខណ្ឌ ១០៦ និង ១០៧ ត្រូវបានធ្វើវិសោធនកម្ម និងកថាខណ្ឌ ១០៦ក ត្រូវបានបន្ថែម តាមរយៈ *ការធ្វើឱ្យប្រសើរឡើងនូវស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ* ដែលបានបោះផ្សាយនៅខែ ឧសភា ឆ្នាំ ២០១០។ អង្គភាពត្រូវអនុវត្តវិសោធនកម្មទាំងអស់នោះសម្រាប់ការិយបរិច្ឆេទដើមឆ្នាំ ដោយគិតចាប់ពីថ្ងៃឬក្រោយថ្ងៃ ១ ខែ មករា ឆ្នាំ ២០១០។ ការអនុវត្តមុន ត្រូវបានអនុញ្ញាត។

១៣៩ឆ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៩ ដែលបានបោះផ្សាយនៅក្នុងខែ តុលា ឆ្នាំ ២០១០ បានធ្វើវិសោធនកម្មកថាខណ្ឌ ៧ ៦៨ ៧១ ៨២ ៩៣ ៩៥ និង ១២៣ និងបានលុបចោលកថាខណ្ឌ ១៣៩ង ។ អង្គភាពត្រូវអនុវត្តវិសោធនកម្មទាំងនោះ នៅពេលដែលអង្គភាពអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៩ ដូចដែលបាន បោះផ្សាយនៅខែ តុលា ឆ្នាំ ២០១០។

១៤០ ស្តង់ដានេះ ជំនួសដោយ ស្តង់ដាគននេយ្យអន្តរជាតិ ១ ស្តីពី *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* ដែលបានកែប្រែឆ្នាំ ២០០៣ និងបានធ្វើវិសោធនកម្ម នៅឆ្នាំ ២០០៥។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋានៈ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែលៈ info@naccambodia.gov.kh | គេហទំព័រៈ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ